Cambodian Farmer Federation
Association of Agricultural Producers
CFAP-CAMBODIA

# បច្ចេកទេសដាំដំណាំ

១. ដំណាំត្រសក់/1. Cucumber

២. ដំណាំម្រះ/2. Bitter gourd

៣. ដំណាំត្រឡាច/4. Winter melon

៤. ដំណាំសណ្តែកគួរ/3. Stringbean

បោះពុម្ពលើកទី៣ ចំនួន១០០០ច្បាប់

គាំទ្រដោយ

© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

# មាតិកា

**ចំណងជើងអត្ថបទ** **ទំព័រ**


១. មាតិកា ៖..........I
២. អារម្ភកថា ៖..........II
៣. បច្ចេកទេសដាំដំណាំដោយប្រើកៅស៊ូគ្របរង៖..........១
៤. បច្ចេកទេសដាំត្រសក់៖..........២-១០
៥. បច្ចេកទេសដាំម្រះ៖..........១១-២៤
៦. បច្ចេកទេសដាំត្រឡាច៖..........២៥-២៨
៧. បច្ចេកទេសដាំសណ្ដែកកួរ៖..........២៩-៣៧
៨. សត្វមានប្រយោជន៍ក្នុងចំការ៖..........៣៨-៤០
៩. សត្វចង្រៃក្នុងចំការ៖..........៤១-៤២
១០.តារាងវិភាគសារធាតុចិញ្ចឹមនៅក្នុងបន្លែ ១០០ក្រាម៖..........៤៣-៤៨
១១.ការប្រើប្រាស់ថ្នាំគីមីកសិកម្មសំរាប់កំចាត់សត្វល្អិតចង្រៃ៖..........៤៩-៥០
៧. អត្ថប្រយោជន៍របស់ជីធម្មជាតិ៖..........៥១
៨. ជីកំប៉ុស្តគោក៖..........៥២-៥៤
៩. ជីកំប៉ុស្តទឹក៖..........៥៥
១០. ជីអ៊ីអឹម៖..........៥៦-៥៨
១១. ថ្នាំកសិកម្មផ្សំពីរុក្ខជាតិ៖..........៥៩-៦១
ឯកសារយោង៖..........៦២
១៤. អ្នកចូលរួមពិភាក្សា និងរៀបចំសៀវភៅបច្ចេកទេស៖..........៦៣




© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## អារម្ភកថា

ឯកសារនេះត្រូវបានចងក្រងដោយ សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម (ស៊ីហ្វាប-កម្ពុជា) ក្រោមការដឹកនាំក្នុងការរៀបចំសៀវភៅនេះឡើងដោយ លោក **សុខ សុថា** ដែលជាប្រធានស្ថាបនិកនិងជាប្រធានប្រតិបត្តិស៊ីហ្វាប-កម្ពុជា ។

យោងតាមសកម្មភាពការងារនៃសមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម ក្នុងការអនុវត្តន៍ការងារដោយផ្ទាល់ជាមួយប្រជាកសិករ សហគមន៍ សមាគមដែលជាសមាជិកនិងក្រៅសមាជិកតាមតំបន់គោលដៅនៃប្រទេសកម្ពុជា ហើយពួកគាត់ជួបការលំបាក ក្នុងការដាំដុះដំណាំ បន្លែ សមស្របតាមបច្ចេកទេស សុវត្ថិភាពខ្ពស់ឆ្លើយតមបានតាមតំរូវការទីផ្សារនាពេលបច្ចុប្បន្ន និងអនាគត។

ការលើកទឹកចិត្តដល់ប្រជាកសិករអោយប្រើប្រាស់ដីកសិកម្មអស់លទ្ធភាពក្នុងការបង្កើនស្បៀងអារហារព្រមទាំងរកប្រាក់ចំណូលផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារ ជាពិសេសកសិករ អ្នកប្រកបរបកសិកម្មនៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា។

សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម សរសេរកាត់ “ ស.ស.ក.ជ ” ជាអក្សរឡាតាំង “ Cambodian Farmer Federation Association of agricultural Producers ” ឈ្មោះជាអក្សរកាត់ ស៊ីហ្វាប-កម្ពុជា “ CFAP-Cambodia ” ជាសមាគមមិនមែនរដ្ឋាភិបាល ធ្វើការដោយផ្ទាល់ជាមួយក្រុមកសិករ សហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគ្រាសខ្នាតតូច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយកាត់បន្ថយភាពក្រីក្រនិងធ្វើអោយប្រសើរឡើងនូវផលិតភាពស្បៀងអាហារប្រកបដោយនិរន្តរភាព។ សមាគម រួមចំណែកក្នុងការលើកកំពស់សន្តិសុខស្បៀង ប្រកបដោយនិរន្តរភាពនៃកសិករដែលរស់នៅជនបទនិងជួយសំរួលការលំបាករបស់កសិករតាមរយៈកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានជាបឋម រួមមាន៖ កម្មវិធីអប់រំ បណ្តុះបណ្តាល ផ្សព្វផ្សាយ វប្បធម៏សង្គមផងដែរ



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម © CFAP Cambodia 2024

ដល់ប្រជាពលរដ្ឋ ដោយមិនមានទំរង់រើសអើងនិន្នាការនយោបាយ ពូជសាសន៍ សាសនា និង ពណ៌សម្បុរឡើយ ។

ខ្ញុំបាទ យើងខ្ញុំសង្ឃឹមថាកូនសៀវភៅបច្ចេកទេសនេះ និងជាជំនួយដ៏ប្រសើរបំផុតសំរាប់ប្រជាកសិករក្នុងការដាំដុះដំណាំ-បន្លែ សមស្របតាមបច្ចេកទេស និងអាចឆ្លើយតបតាមតំរូវការទីផ្សារនាពេលបច្ចុប្បន្ន និងអនាគត។

ខ្ញុំបាទ យើងខ្ញុំសូមគោរពជូនពរដល់ប្រជាកសិករទាំងអស់នៅទូទាំងប្រទេសទទួលបានជោគជ័យក្នុងការប្រកបរបរដាំដុះដំណាំ-បន្លែ ក៏ដូចជាមុខរបរបន្ទាប់បន្សំដទៃទៀតក្នុងការចិញ្ចឹមជីវិត ជីវភាពល្អប្រសើរ និងរស់នៅប្រកបដោយភាពសុខដុមរមនាក្នុងសង្គម ។

ថ្ងៃទី ........ខែ ធ្នូ ឆ្នាំ ២០២៤

ប្រធានស្ថាបនិកនិងជាប្រធានប្រតិបត្តិ



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## **អ្នកចូលរួមពិភាក្សា និងរៀបចំសៀវភៅបច្ចេកទេស**

- លោក **សុខ សុថា** ប្រធានស្ថាបនិកនិងជាប្រធានប្រតិបត្តិ សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម (**CFAP-Cambodai**)
- លោក **យញ្ញ ធឿន** ទីប្រឹក្សាបច្ចេកទេសកសិកម្ម នៃសមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម
- លោក លោកស្រី បុគ្គលិក ទីប្រឹក្សាសមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម ជាច្រើនរូបទៀត។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

# ឯកសារយោង

១. វគ្គបណ្តុះបណ្តាលសាលារៀនស្រែកសិករលើដំណាំបន្លែ និងការធ្វើពិសោធន៍តាមវិធីសាស្ត្រគ្រប កៅស៊ូលើរង (រៀបចំដោយអង្គការ **IDE** ក្នុងកិច្ចសហការជាមួយ សមាគមស៊ីហ្វាបកម្ពុជា **CFAP** និងគាំទ្រដោយ **SNV**)

២. រូបភាពសកម្មភាពអនុវត្តផ្ទាល់លើរងបង្ហាញរបស់កសិករនៅតាមតំបន់គោលដៅនៃសមាគមស៊ីហ្វាបកម្ពុជា **CFAP**



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

# បច្ចេកទេសដាំដំណាំ ដោយប្រើកៅស៊ូគ្របរង

## ១-បុព្វបទ ៖

ដើម្បីទទួលបានជោគជ័យលើផលិតកម្មដំណាំបន្លែ យើងចាំបាច់ត្រូវតែយល់ដឹងនូវកត្តាចាំបាច់មួយចំនួនដែលវាមានទំនាក់ទំនងជាមួយដំណើរការផលិតកម្មក្នុងនោះរួមមាន ការជ្រើសរើសពូជ ការគ្រប់គ្រងកត្តាចង្រៃ ការគ្រប់គ្រង ដីជាតិដី ការស្រោចស្រព និងវិធីសាស្ត្រអនុវត្តការដាំដុះ។ ការដាំដុះដំណាំ តាមវិធីសាស្ត្រគ្របគល់ដំណាំ គឺជាវិធីសាស្ត្រដ៏សមស្របមួយដែលកសិករទូទៅបានចាប់ ផ្តើមអនុវត្តនិងប្រើប្រាស់តាមរបៀបខុសៗគ្នាដោយនៅរដូវវស្សាកសិករនិយមដាំគ្របរងដោយប្រើប្រាស់កៅស៊ូប្លាស្ទិចព្រោះ រដូវវស្សារមានភ្លៀងជោគជាំ ហើយការគ្របកៅស៊ូវាអាចជួយការកាត់បន្ថយការជាំទឹក របស់ដំណាំការពារកុំអោយស្មៅដុះ រក្សាបានការជ្រាបចេញនៃជីដែលបានដាក់ និងជួយឱ្យដំណាំដុះលូតលាស់បានល្អ ។ ការប្រើប្រាស់កៅស៊ូគ្របរងដំណាំ វាមានប្រសិទ្ធភាពខ្ពស់សំរាប់ដំណាំគ្រប់ប្រភេទទាំងអស់នូវរដូវវស្សាហើយប្រជាកសិករដែលដាំដំណាំកំពុងបានប្រើប្រាស់យ៉ាងច្រើន ។

## ២-គោលបំណង ៖

- កំណត់បាននូវវិធីសាស្ត្រដាំដុះដ៏សមស្របដែលកសិករអាចទទួលយកបាន
- គណនាផលចំណេញដែលទទួលបានក្នុងផលិតកម្មបន្លែ តាមរយៈបច្ចេកទេសដាំដុះដោយមានការប្រើប្រាស់កៅស៊ូគ្របរង
- កសិករយល់ពីអត្ថប្រយោជន៍ និងអនុវត្តតាមបច្ចេកទេស
- ចងក្រងឯកសារបច្ចេកទេសដាំដុះបន្លែសំរាប់កសិករ



© CFAP Cambodia 2024

# ដំណាំត្រសក់ចំណារ

ត្រសក់ចំណារ (គូគូមីស សាទីវុស) គឺជាដំណាំបន្លែយកផ្លែ ដែល ត្រូវបានគេស្គាល់ និង ពេញនិយមក្នុងការប្រើប្រាស់ធ្វើជាអាហារប្រចាំថ្ងៃ នៅទូទាំងពិភពលោក វាមានប្រភពដើមនៅក្នុងប្រទេសឥណ្ឌា និងជា បន្លែ បុរាណមួយ ដែលគេបានធ្វើការដាំដុះតាំងពី ៣០០០ឆ្នាំមុន រហូតដល់ បច្ចុប្បន្ននេះ និងបានរាលដាល យ៉ាងឆាប់រហ័ស នៅពាសពេញទ្វីបអាស៊ី និង ទ្វីបអ៊ឺរ៉ុប ក្នុងកំឡុងសតវត្សទី៦ និង សតវត្សទី៧ ហើយគេបានធ្វើចំណាត់ថ្នាក់វាចូលទៅក្នុងគ្រួសារ គុយគូបីតាសេ។ ចាប់ពីពេលដាំដុះរហូតដល់ ពេល ប្រមូលផលចប់រួចរាល់ ត្រសក់មានអាយុកាល ៦៥ថ្ងៃ ដល់ ៨០ថ្ងៃ ការប្រែប្រួលនៃអាយុកាលរបស់វា គឺអាស្រ័យទៅលើបរិស្ថាន ទីកន្លែងដាំដុះ និង ប្រភេទពូជ ដែលបានដាំផងដែរ ហើយចាប់ពីពេលដាំរហូតដល់ចេញផ្កា មានរយៈ ពេលពី ៣៥-៤៥ថ្ងៃ និង ចាប់ពីពេលដាំរហូតដល់ពេលប្រមូលផល លើកដំបូង មានរយៈ ពេលពី ៤៥-៥៥ថ្ងៃ។

## ១. លក្ខខណ្ឌដុះលូតលាស់របស់ដាំត្រសក់

ជាទូទៅ ដំណាំត្រសក់អាចដុះលូតលាស់បានល្អ នៅក្នុងសីតុណ្ហភាព ជាមធ្យក្នុងចន្លោះពី ២០-៣០ អង្សាសេ តែសីតុណ្ហភាព ដែលល្អបំផុតសំរាប់វាគឺក្នុង ចន្លោះពី ២២-២៣អង្សាសេ។ ចាំបាច់ត្រូវ មានពន្លឺគ្រប់គ្រាន់ ក្នុងរយៈពេល ពី ១០-១១ ម៉ោងក្នុងមួយថ្ងៃ។ ដីដែលសមស្របសម្រាប់ការដាំដុះត្រសក់គឺជាប្រភេទដីល្បប់ល្បាយខ្សាច់ដែល មានជីជាតិល្អ ហើយមិនជាំទឹកនិងមាន ប៉េហាស់ (ផេះ) ចន្លោះពី ៥,៨ - ៦,៨ ។

ចំពោះតម្រូវការ ពន្លឺ គឺជាកត្តាមួយសំខាន់សំរាប់ការដុះលូតលាស់ និងធ្វើ រស្មីសំយោគរបស់ ត្រសក់ ដូច្នេះ ដើម្បីជួយអោយ ត្រសក់ ដុះលូតលាស់ បានល្អ ទីកន្លែងដាំដុះ ក្នុង



- វល្លិ៍បណ្តូលពេជ្រ ចំនួន ២គីឡូក្រាម
- មើមក្តួចព្រៃ ចំនួន ២គីឡូក្រាម
- សំបកកន្ទួត ចំនួន ២គីឡូក្រាម
- ប្រង់ព្រៃ ចំនួន ៥គីឡូក្រាម
- ទឹកធម្មតា ១០-១២លីត្រ
- ម្សៅសាប៊ូ ចំនួន ១ក្តាប់ដៃ

## II. សំភារៈធ្វើថ្នាំពុលផ្សំពីរុក្ខជាតិ

- ពីដុង ឬ កូនពាងចំណុះ ៣០លីត្រ
- កំប៉ុងទឹកដោះគោ
- ស្បៃចាស់ (សម្រាប់ច្រោះ ក្នុងករណីប្រើបំពង់បាញ់ថ្នាំ)

## III. របៀបធ្វើ

- យកគ្រឿងផ្សំ ដែលមានខាងលើ បុកដាក់ចូលពីដុង ឬ កូនពាង
- ទុករយៈពេល ៧-១០ ថ្ងៃទើបអាចប្រើបាន

## IV. របៀបប្រើប្រាស់

- ទឹកថ្នាំកន្លះកំប៉ុងទឹកដោះគោ លាយជាមួយទឹកធម្មតាចំនួន ១-២លីត្រ លាយជាមួយម្សៅសាប៊ូ ចំនួន ១ស្លាបព្រា (បាញ់នៅពេលកូនបន្លែនៅតូច)
- ទឹកថ្នាំមួយកំប៉ុងទឹកដោះគោ លាយជាមួយទឹកធម្មតាចំនួន ១-២លីត្រ និងម្សៅ ចំនួន ១ស្លាបព្រាបាយ (បាញ់នៅពេលបន្លែធំ )
- រៀងរាល់ ២-៣ថ្ងៃបាញ់ម្តង



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## II. វត្ថុធាតុដើម

- ស្លឹកទន្ទ្រានខែត្រចំនួន ១គីឡូក្រាម
- ថ្នាំជក់ (ថ្នាំខ្លាំងចំនួន ២ខាំ)
- ទឹកធម្មតាចំនួន ៥លីត្រ

## III. របៀបធ្វើ

- យកថ្នាំខ្លាំង ទឹក ស្លឹកទន្ទ្រានខែត្រដាក់លាយចូលគ្នាក្នុងឆ្នាំង
- ស្ងោរអោយពុះ
- ទុកឱ្យត្រជាក់ចាំយកមកប្រើប្រាស់

## IV. របៀបប្រើប្រាស់

- ប្រើទឹកថ្នាំសុទ្ធ (មានប្រសិទ្ធភាពខ្ពស់ទៅលើពពួកចៃនៅលើដំណាំ)

# ថ្នាំកសិកម្មផ្សំពីរុក្ខជាតិច្រើនមុខ

## I. គ្រឿងផ្សំ

- រំដេងព្រៃ ចំនួន ៣គីឡូក្រាម
- ស្លឹកគ្រៃ ចំនួន ៣ខាំ
- សំបកស្ដៅ ចំនួន ២គីឡូក្រាម
- ថ្នាំខ្លាំង ចំនួន ២ខាំ



គឺគេអាចដាំត្រសក់បាន ២រដូវ គឺថា រដូវរំហើយ ចាប់ពីខែ តុលា រហូតដល់ខែធ្នូ និង រដូវវស្សា ចាប់ពីខែ កក្កដា រហូតដល់ខែ សីហា។ ប្រសិនបើយើងអនុវត្តការដាំដុះតាមបច្ចេកទេស ដែលមានដូចជា ការប្រើ កៅស៊ូគ្របលើរង ឬ ការប្រើសំណាញ់កាត់បន្ថយកំដៅជាដើម នោះយើងអាចដាំត្រសក់បានពេញមួយឆ្នាំ ប៉ុន្តែអ្នកដាំដុះ ចាំបាច់ត្រូវចំណាយធនធានមួយចំនួនសំរាប់ទិញសម្ភារទាំងនោះ។

### ២.បច្ចេកទេសដាំដុះត្រសក់

#### ២.១. ការជ្រើសរើសពូជ

ការជ្រើសរើសពូជ ត្រូវពឹងផ្អែកលើ កត្តាសំខាន់ៗ មួយចំនួន ដូចខាង ក្រោម:

- ពូជមិនប្រកាន់រដូវ និង ពូជធន់នឹងជំងឺ ផ្សេងៗដែល តែងតែកើត មាន នៅក្នុងតំបន់ដាំដុះ។
- ប្រភេទពូជ ដែលអ្នកបរិភោគនិយមច្រើន និងមាន តម្រូវការ ទីផ្សារខ្ពស់។










© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម
© CFAP Cambodia 2024

**២.២.ការរៀបចំដី និងលើករងសំរាប់ដាំដុះ**

- ភ្ជួរហាលដី ភ្ជួរដីជម្រៅ 20-25cm (ស្មើនឹង ២-២,៥ តឹក) ហើយហាលដីទុកចោលក្នុងរយៈពេល ៧-១០ ថ្ងៃ។

- **<u>លើករង</u>ក្នុងទំហំ** 0.8m (ស្មើនឹង ៨ តឹក) និង កំពស់ 25-30cm (ស្មើនឹង២,៥-៣តឹក)ចន្លោះពីរងមួយទៅរងមួយទៀតមានប្រវែង 0.5m (ស្មើនឹងកន្លះម៉ែត្រ)។

- **<u>ការប្រើជីទ្រាប់បាត</u> ឬជីលាមកសត្វក្នុងកម្រិត ៣០ គីឡូក្រាមក្នុងមួយរងលាយជាមួយកំបោរកសិកម្មចំនួន ៨ ខាំ ក្នុងមួយរង និងជី** 15-15-15 ចំនួន ២.៥ ខាំក្នុងមួយរង។ លាយច្របល់ជី និងកំបោរកសិម្មចូលទៅក្នុងដីឱ្យបានស្មើសាច់ល្អ ហើយស្រោចទឹកឱ្យជោគដីល្មម រួចក្រាលកៅស៊ូគ្របលើរងហើយរក្សាទុក រយៈពេលពី ៧-១០ ថ្ងៃមុនពេលដាំ ។

រូបភាពទី១៖ ការរៀបចំរងដាំត្រសក់





**ឧបសម្ព័ន្ធ៥**

# ថ្នាំកសិកម្មផ្សំពីរុក្ខជាតិសម្រាប់ប្រើប្រាស់លើដំណាំបន្លែ

## - ថ្នាំកសិកម្មផ្សំពីរុក្ខជាតិ២មុខ
## - ថ្នាំកសិកម្មផ្សំពីរុក្ខជាតិច្រើនមុខ
## - ថ្នាំកសិកម្មផ្សំពីរុក្ខជាតិមួយមុខ

**<u>គោលបំណង៖</u>** គោលបំណងនៃការប្រើប្រាស់ថ្នាំកសិកម្មផ្សំពីរុក្ខជាតិ គឺកាត់បន្ថយការចំណាយទៅលើការទិញថ្នាំគីមីកសិកម្ម ព្រោះការប្រើប្រាស់ថ្នាំកសិកម្មផ្សំពីរុក្ខជាតិ មិនធ្វើឱ្យប៉ះពាល់ដល់សុខភាពឡើយ និងធ្វើឱ្យបន្លែ មានរសជាតិឆ្ងាញ់ និងមានតំលៃនៅលើទីផ្សារទៀតផង។

**I. សម្ភារធ្វើថ្នាំកសិកម្មផ្សំពីរុក្ខជាត**

- ឆ្នាំងសំរាប់ស្ងោរ
- ចង្ក្រានអូសដុត



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## V. ការថែរក្សា

- ពីដុងដែលយើងបានដាក់ជីនោះ ត្រូវបើកគំរបសិនទើបក្រឡុក ឬកូរ ១ដង/ថ្ងៃ
- ពេលបើកគម្របពីដុងក្រឡុករួចហើយត្រូវបិទទៅវិញឱ្យជិតល្អ
- ទុកពីដុងទឹកជីក្នុងម្លប់ ជៀសវាងកុំឱ្យត្រូវថ្ងៃ។

## VI. គំរិតប្រើប្រាស់

- ទុកទឹកជីដែលយើងបានលាយនោះរយៈពេល ពី ១០ ទៅ ១៥ ថ្ងៃ ទើបអាចយកទៅប្រើបាន
- យកទឹកជី កន្លះកំប៉ុងទឹកដោះគោ លាយជាមួយទឹកធម្មតាចំនួន ២០លីត្រ
- ស្រោចដំណាំជារៀងរាល់ ៤ ទៅ ៥ ថ្ងៃម្តង
- លាយជាមួយបាយ អោយជ្រូកស៊ី ឆាប់ធំធាត់។

## VII. របៀបប្រើប្រាស់

✺ ផ្អាប់ជីទុករយៈពេល ២-៣សប្តាហ៍ ទើបអាចប្រើបាន
✺ ទឹកជី ១លីត្រ លាយទឹកធម្មតា៥លីត្រ សម្រាប់ស្រោចបន្លែពេញវ័យ
✺ ទឹកជី ១លីត្រ លាយទឹកធម្មតា១០លីត្រ សម្រាប់ស្រោចកូនបន្លែ។



### ២.៣.របៀបបណ្តុះកូន

- សាបគ្រាប់នៅក្នុងកន្ទោងឬថាសបណ្តុះកូន ឬសម្ភារក្នុងស្រុកអាចធ្វើជំនួសបាន
- ល្បាយដីបណ្តុះកូន ត្រូវដុតកំដៅសម្លាប់មេរោគ មុនពេលយកវាមកប្រើ
- ប្រើថ្នាំការពារជំងឺផ្សិត លាយជាមួយគ្រាប់ពូជមុនពេលយកវាទៅបណ្តុះ។ វិធីប្រើថ្នាំផ្សិត គឺបន្ទាប់ពីត្រាំគ្រាប់ ១៥-២០ នាទី ត្រូវយកទឹកស្អាត ១កែវ លាយជាមួយថ្នាំផ្សិត ១ស្លាបព្រាកាហ្វេ រួចកូរអោយសព្វត្រាំទុករយៈពេល ១៥-២០នាទី បន្ទាប់មកលាងសំអាតជាមួយទឹកស្អាត ទើបយកទៅផ្អាប់ក្នុងថូទឹកកក ដោយគ្របអោយបានជិត រក្សាទុក ១យប់ទើប យកគ្រាប់ពូជនេះ ទៅបណ្តុះក្នុងកន្ទោង រយៈពេលពី ៥-៧ ថ្ងៃ កូនដំណាំអាចដាំបាន ។

រូបភាពទី២៖ ការរៀបចំត្រាំគ្រាប់ត្រសក់ និងការបណ្តុះកូនត្រសក់





© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

**២.៤.របៀបដាំដុះ**

- ដាំ ២ជួរ ក្នុងមួយរង ហើយចន្លោះគុម្ព 0.5m (ស្មើនឹងកន្លះម៉ែត្រ) ហើយដាំនៅតាមចំហៀងរង។

- ចំនួនគុម្ពសរុប = 40 គុម្ពក្នុងមួយរង x 5 រង = 200 គុម្ព។

**២.៥.ការប្រើប្រាស់ជីបំប៉នក្រោយដាំ**

**- ជីបំប៉នលើកទី១ ប្រើជី** FDP (ជីគ្រាប់ធំ) ចំនួន ១គ្រាប់ ក្នុងមួយគុម្ព ដាក់បង្កប់ក្នុងដីជំរៅ និងចំងាយ 10cm (ស្មើនឹង ១តឹក) ពីគុម្ពដំណាំ ហើយដាក់នៅពេលពូនគល់ដំបូង ឬពេល ដាក់ទ្រើង។




រូបភាពទី ៣ ការដាក់ជីបំប៉ន

**- ជីបំប៉នលើកទី២ ប្រើជី** FDP (ជីគ្រាប់ធំ) ចំនួន ១គ្រាប់ ក្នុងមួយគុម្ព ដាក់បង្កប់ក្នុងដីជំរៅនិងចំងាយ 10cm (ស្មើនឹង១តឹក) ពីគុម្ពដំណាំហើយដាក់នៅពេលត្រសក់ចេញផ្កាដំបូង ។

**- ជីបំប៉នលើកទី៣ ប្រើជីអ៊ុយរ៉េក្នុងកម្រិត ៣ក្រាម ក្នុងមួយគុម្ពដាក់ បង្កប់ក្នុងដីក្បែរគុម្ពដំណាំ នៅក្រោយពេលប្រមូលផលលើកដំបូងរួច។ វិធីមួយទៀតយើងអាច**

**- យកជីអ៊ុយរ៉េ ១ស្លាបព្រាបាយ លាយជាមួយទឹក ១០លីត្រ ស្រោចលើដំណាំមួយរង ដែលមានបណ្តោយ ១០ម៉ែត្រ ។**



**III. របៀបលាយវត្ថុធាតុដើម**

- លាយកន្ទក់ និងដីម៉ត់ឱ្យបានសព្វល្អ

- លាយស្ករជាមួយទឹក រួចចាក់ចូលទៅក្នុងល្បាយដី ដែលបានលាយជាមួយកន្ទក់រួចហើយ

- រួចច្របល់ល្បាយខាងលើអោយបានសព្វល្អ

- ពិនិត្យមើលកុំអោយសើម ឬ ស្ងួតពេក (ល្មមពូតជាប់គ្នាដូចដីឥដ្ឋ)

- ខ្ចប់ដីដែលលាយរួចហើយជាមួយក្រណាត់ពណ៌ស

**IV. របៀបធ្វើឱ្យនៅជាជីអ៊ីអឹម**

- ទុកកញ្ចប់ដីដែលយើងខ្ចប់រួចហើយក្នុងម្លប់ រយៈពេល៣យប់ (មិនឱ្យត្រូវពន្លឺថ្ងៃទេ )

- ពិនិត្យមើល បើសិនមានផ្សិតពណ៌ស តូចៗ ដុះចេញពីដីដែលយើងខ្ចប់នោះ ជីដែលយើងបានធ្វើពិតជា ជីត្រឹមត្រូវហើយ

- ទឹកធម្មតាចំនួន ២០លីត្រ លាយជាមួយស្ករត្នោតធុនអន់ ចំនួន ១គីឡូក្រាម ដាក់ចូលក្នុងពីដុង រួចក្រឡុកឱ្យរលាយចូលគ្នាស្មើសាច់

- ច្របាច់ដុំជី ដែលយើងបានផ្អាប់ទុកនោះ ឱ្យរាយទាំងអស់ ទើបដាក់ចូលក្នុងពីដុង រួចក្រឡុកឱ្យសព្វល្អ។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

# E.M ជីអ៊ីអឹម

## I. វត្ថុធាតុដើមសំរាប់ធ្វើជីអ៊ីអឹម

-កន្ទក់ម៉ត់ ដែលមានជាតិអង្ករ ចំនួន ១គីឡូក្រាម

- ដីធម្មតា (ដីដែលគ្មានភ្លើងឆេះ) ចំនួន ១គីឡូក្រាម

- ទឹកធម្មតា ចំនួន ១លីត្រ (មិនប្រើទឹកម៉ាស៊ីន ឬទឹកអណ្តូងស្នប់ទេ)

- ស្ករត្នោត (ស្ករធុនអន់បំផុត) ចំនួន ១គីឡូក្រាម

## II. សម្ភារសំរាប់ធ្វើ

- ពិដុង ឬ កានថ្មី ចំណុះ៣០លីត្រ

- កញ្ច្រែញ្ញរែងដី

- ក្រណាត់ស (ហាមប្រើក្រណាត់ពណ៌ )

- ប្រដាប់លាយ (ចានដែក កាធុន....)



## ៣. ការគ្រប់គ្រងសត្វល្អិតចង្រៃ និងជំងឺ

### *៣.១ ការគ្រប់គ្រងសត្វល្អិតចង្រៃ*

#### *ក. រុយស*

**វិធានការគ្រប់គ្រងនឹងកំចាត់**

- ប្រើបន្ទះប្លាស្ទិកពណ៌លឿង ធ្វើអន្ទាក់សំរាប់ទាក់ទាញមេចំណាស់ដោយមានលាបថ្នាំឬប្រេងស្អិតៗ

- ប្រើក្លិនម្រះព្រៅម្យ៉ាងដើម្បីចាប់រុយសយកទៅបំផ្លាញចោល

- ប្រើថ្នាំកសិកម្មផ្សំពីរុក្ខជាតិស្ដៅមកបាញ់លើត្រសក់ នៅក្នុងដំណាក់កាលពងរបស់រុយសមិនទាន់ញាស់

- ប្រើថ្នាំអាកតារ៉ា ឬថ្នាំអាបាមិចទីនអាចមានប្រសិទ្ធភាពល្អ ក្នុងការ ទប់ស្កាត់ការបំផ្លាញ ប៉ុន្តែត្រូវប្រើតាមការណែនាំរបស់ស្លាកថ្នាំ ដើម្បីជៀសវាងការ បំពុលដល់ បរិស្ថានជាពិសេស គឺប៉ះពាល់ខ្លាំងដល់ពពួកសត្វមានប្រយោជន៍។ **(សូមមើលឧបសម្ព័ន្ធ២)**

#### *ខ. ចៃបៃតង និងចៃក្រហម*

**វិធានការគ្រប់គ្រងនឹងកំចាត់**

- ប្រើប្រាស់ថ្នាំពុលដែលផ្សំពីរុក្ខជាតិលាយជាមួយទឹក ហើយបាញ់រៀងរាល់ ១សប្តាហ៍ម្តងដើម្បីការពារការបំផ្លាញ។ ក្នុងករណីធ្ងន់ធ្ងរប្រើថ្នាំពុលគីមី **ភុខហ្វីដ័រ**

**កំរិតប្រើប្រាស់:** ត្រូវលាយថ្នាំ ១០សេសេ ជាមួយទឹកចំនួន១០លីត្រ បាញ់លើផ្ទៃដីដំណាំ ១០០ម៉ែត្រការ៉េ ។

**លក្ខខណ្ឌនៃការប្រើប្រាស់:** កំណត់ការបាញ់ថ្នាំនេះ ក្នុងរយៈពេលពី ១០ទៅ ១៥ថ្ងៃ មុនពេលប្រមូលផល ។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

**ពេលវេលាត្រូវបាញ់:** ត្រូវបាញ់នៅពេលព្រឹកព្រលឹម ឬ ពេលល្ងាច ។

**ការប្រុងប្រយ័ត្ន:** ត្រូវពាក់របាំងមុខ ស្រោមដៃ និងសំលៀកបំពាក់ការពារខ្លួនឱ្យបានល្អ នៅពេលបាញ់ថ្នាំ ។

*៣.២ ជំងឺលើដំណាំត្រសក់*

*ក. ជម្ងឺស្រពោនដើម*

**វិធានការគ្រប់គ្រងនឹងកំចាត់**

យើងអាចការពារនឹងកំចាត់ជំងឺនេះបានដោយបណ្ដុះកូននៅក្នុងកន្ទោងដែលយើងបានសម្លាប់មេរោគនៅក្នុងដី។ ប្រសិនបើ វាធ្វើការបំផ្លាញធ្ងន់ធ្ងរ យើងអាចប្រើថ្នាំ មេតាក់សីល (Methaxyl) ឬថ្នាំ ហ្វូសេទីល (Fosetyl-Al) មកបាញ់ការពារនៅលើស្លឹក នឹងនៅលើដីគឺអាចកាត់បន្ថយជំងឺនេះ ។

**៤. ការស្រោចស្រព និងគ្រប់គ្រងទឹក៖**

ត្រូវស្រោចស្រពដំណាំ ឱ្យបានទៀងទាត់ពេលវេលា និងរក្សាសំណើមដីឱ្យស្ថិតនៅក្នុងកម្រិតមួយ សមស្របតាមប្រភេទដី។ ចំពោះប្លង់ពិសោធន៍ ដែលប្រើកៅស៊ូប្លាស្ទិចគ្របរងយើងអាចស្រោចស្រព តាមវិធីសាស្ត្របង្ហូរទឹកតាមចន្លោះរងនីមួយៗបាន ហើយក្នុងករណីដែលមានភ្លៀងគ្រប់គ្រាន់ ការស្រោចស្រព គឺពុំចាំបាច់ឡើយ ហើយបរិមាណទឹកដែលត្រូវស្រោចគឺពី ៣ - ៥ លីត្រ សំរាប់ផ្ទៃដីដាំដុះចំនួន ១ ម៉ែត្រការេ។



# ជីកំប៉ុស្តទឹក

**I. សំភារៈសំរាប់ធ្វើជីកំប៉ុស្តទឹក**

- ពាង បាវក្រចៅ
- ដុំថ្មសម្រាប់សង្កត់ជី
- កំប៉ុងទឹកដោះគោ

**II. វត្ថុធាតុដើម**

- ជីស្រស់ចំនួន ១០ គីឡូក្រាម
- លាមកគោស្រស់ចំនួន ១៥-២០ គីឡូក្រាម
- ទឹកធម្មតាចំនួន ១៥០-២០០លីត្រ (១០ ទៅ ១៤ធុង )។

**III. របៀបធ្វើ**

- ដាក់ដុំថ្មចូលក្នុងបាវក្រចៅផ្នែកខាងក្រោម ដើម្បីឱ្យបាវជីលិចទៅក្នុងទឹក
- ដាក់ជីស្រស់ដែលបានចិញ្ច្រាំរួចហើយ និងលាមកសត្វដាក់ចូលក្នុងបាវ រួចចងមាត់ឱ្យជិត តែកុំចងណែនពេក ដោយទុកពីខ្សែចំណងឃ្លាតពីជីប្រមាណមួយចំអាមដៃ ព្រោះជីពេលត្រូវទឹកវានឹងរីកមាឌ
- យកដុំថ្ម ឬកំណាត់ឈើសង្កត់ពីលើបាវដែលដាក់ជីរួចហើយ ដើម្បីឱ្យបាវជីលិចទៅក្នុងទឹក
- គ្របពាងជីឱ្យបានជិតល្អ និងយកឈើកូរវាជារៀងរាល់ថ្ងៃ ដើម្បីឱ្យជីឆាប់កាច់។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## ស្រទាប់ដែលត្រូវរៀបក្នុងរោងជីកំប៉ុស្ត

| | |
|---|---|
| ស្រទាប់ទី៤: | ដាក់ដីបាតត្រពាំង ឬ ដីដំបូកកំរាស់ ០.៥០តឹក |
| ស្រទាប់ទី៣: | ដាក់លាមកសត្វ  អាចម៍គោ ក្របី ជ្រូក មាន់ទា កំរាស់ ០.៥០តឹក |
| ស្រទាប់ទី២: | ដាក់ជីស្រស់ ទន្ទ្រានខែត្រ ពីលើកំរាស់ ១.៥០តឹក |
| ស្រទាប់ទី១: | ដាក់ស្លឹកឈើស្ងួត ឬ ចំបើង ខាងក្រោមកំរាស់ ១តឹក |

**ចំណាំ៖** ត្រូវយកចេញនូវវត្ថុធាតុណាដែលមិនរលួយ  ដូចជា សំបកកំប៉ុង ជ័រកៅស៊ូ ដែក អំបែងកែវ...។ល។

### VI. របៀបប្រើប្រាស់៖

ជីកំប៉ុស្តដែលអាចយកទៅប្រើប្រាស់បាន  គឺនៅពេលដែលជីនោះរលួយល្អ  មានរយៈពេល ២-៣ ខែ បន្ទាប់ពីធ្វើកំរិតប្រើប្រាស់យកទៅដាក់ស្រែគឺ ១០-២០ តោន លើផ្ទៃដី ១ ហិកតា។

មុនយកជីកំប៉ុស្តទៅប្រើត្រូវយកដៃលូកក្នុងគំនរកំប៉ុស្តបើត្រជាក់អាចប្រើបាន ហើយ បើក្តៅទុកបន្ត។



### ៥. ការប្រមូលផល

រយៈពេលទទួលផលត្រសក់គឺប្រែប្រួលទៅតាមប្រភេទពូជ និងទីកន្លែងដែល បានដាំដុះ ប៉ុន្តែជាទូទៅ យើងអាចចាប់ផ្តើម ប្រមូលផលក្នុង រយៈពេល ៤០-៥០ថ្ងៃ ក្រោយពេលដាំ។ ប្រសិនបើ ត្រសក់ ដុះលូតលាស់ល្អ គេអាចប្រមូលផលបានពី ៨-១២ លើក ហើយអាចទទួលទិន្នផលបានចាប់ពី  ២០-២៣៥តោន/ហ,ត  អាស្រ័យទៅតាមពូជ  ការដាំដុះ និងការថែទាំ។ បច្ចុប្បន្ន នៅតាមបណ្តាប្រទេសមួយចំនួន អាចទទួលបាន ទិន្នផលរហូតដល់ ៣០-៦០តោន/ហត ។



### ៦. ការតាមដានស្រែពិសោធន៍ និងប្រមូលទិន្នន័យ

#### ៦.១. ទិន្នន័យរបស់ដំណាំដែលត្រូវប្រមូលរួមមាន

- ឈ្មោះដំណាំ និងប្រភពពូជ
- ផ្ទៃដីដាំដុះសរុប
- ចំនួនគុម្ពដំណាំ ដោយរាប់ក្នុងដំណាក់កាលប្រមូលផលលើកដំបូង
- ថ្ងៃ.ខែ.ឆ្នាំដាក់ជីបំប៉ន និងបរិមាណដែលប្រើ
- ទិន្នផល ប្រាក់ចំណូល និងថ្ងៃ.ខែ ដែលបានប្រមូលផលក្នុងមួយលើកៗ



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

- វិធីសាស្ត្រស្រោចស្រព

- ប្រភេទសត្វល្អិត និងជំងឺដែលកើតមានច្រើនជាងគេ

**៦.២. ទិន្នន័យផលិតកម្ម**

- កត់ត្រារាល់ការចំណាយ លើសម្ភារផលិតកម្មដោយរាយមុខចំណាយ និងតម្លៃសរុបរបស់សម្ភារនីមួយៗដែលបានទិញសំរាប់ដំណើរការផលិតកម្មដំណាំ។

- តម្លៃប្រតិបត្តិនៅលើទីផ្សារ ដូចជាដឹកជញ្ជូន វេចខ្ចប់ ពន្ធលក់ដូរជាដើម។

- តម្លៃពលកម្ម ឧទាហរណ៍ ជួលពលកម្មរៀបចំដី បាញ់ថ្នាំ....។ល។

## ៧. គំរោងថវិកាសម្រាប់ប្លង់ពិសោធន៍ ដំណាំត្រសក់ទ្រើង

| រាយមុខចំណាយ | ឯកត្តា | បរិមាណ | ថ្លៃឯកត្តា(រៀល) | សរុប(រៀល) |
|---|---|---|---|---|
| គ្រាប់ពូជត្រសក់ 331 | កញ្ចប់ | ២ | ១០.០០០ | ២០.០០០ |
| កៅស៊ូគ្របរង | ម៉ែត្រ | ៥០ | ៤០០ | ២០.០០០ |
| កំបោរកសិកម្ម | គ.ក្រ | ៥ | ១.០០០ | ៥០០០ |
| ថាសបណ្តុះកូន | បន្ទះ | ២ | ៥០០០ | ១០.០០០ |
| ជីគ្រាប់ធំ **FDP** | គ.ក្រ | ២ | ៤.០០០ | ៨.០០០ |
| ជីគីមី១៥-១៥-១៥ | គ.ក្រ | ២ | ៣.០០០ | ៦.០០០ |
| ថ្នាំផ្សិត | កញ្ចប់ | ១ | ១០.០០០ | ១០.០០០ |
| **សរុបចំណាយ** | | | | ៧៩.០០០ |



ស្រទាប់ទី២: ដាក់ជីស្រស់ (ទន្ទ្រានខែត្រ) ពីលើកំរាស់ ១.៥០តឹក

ស្រទាប់ទី៣: ដាក់លាមកសត្វ(អាចម៍គោ ក្របី ជ្រូក មាន់ទា) កំរាស់ ០.៥០តឹក

ស្រទាប់ទី៤: ដាក់ដីបាតត្រពាំង ឬ ដីដំបូកកំរាស់ ០.៥០តឹក បោះបង្គោលឬស្សីដែលមានប្រហោងនៅចំកណ្តាលរណ្តៅជីដើម្បីឱ្យមានខ្យល់ចេញចូលល្អដល់ស្រទាប់ក្រោម និងងាយស្រួលជ្រាបទឹកពីលើដល់ក្រោមស្រោចទឹក២-៣ដង ក្នុងមួយថ្ងៃជារៀងរាល់ថ្ងៃ។

ធ្វើសារឡើងវិញដូចពីមុនដោយរៀបជាស្រទាប់ៗ រហូតដល់គំនរកំប៉ុស្តមានកំពស់ ១-១.៥០ម៉ែត្រ

ក្រោយពីធ្វើរួចរយៈពេល ៣សប្តាហ៍ ត្រូវត្រឡប់គំនរកំប៉ុស្តសារជាថ្មីដោយយកស្រទាប់ខាងក្រោម មកដាក់ខាងលើ និងយកស្រទាប់ខាងលើមកដាក់ខាងក្រោមវិញ

បន្ទាប់ពីបានរយៈពេល ៥សប្តាហ៍ ត្រូវត្រឡប់គំនរជីកំប៉ុស្តម្តងទៀតដោយត្រឡប់ស្រទាប់ទាំងនោះដាក់ក្នុងសភាពដើមវិញ និងទុកអោយគំនរជីកំប៉ុស្តរលួយរយៈពេល ៥សប្តាហ៍ បន្ថែមទៀត។








© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

# ជីកំប៉ុស្តគោក

**សមាជិករបស់ក្រុមដំណាំបន្លែទាំងអស់ ត្រូវតែធ្វើរោងជីអោយបានគ្រប់គ្នា ដើម្បីអោយមានជីធម្មជាតិ សម្រាប់ដាក់ដំណាំគ្រប់ប្រភេទ និង កាត់បន្ថយការប្រើប្រាស់ជីគីមី។**

**ទំហំរោងជីដែលត្រូវសាងសង់** ៖ ទំហំ ២ x ៣ ម៉ែត្រ កំពស់ ១.៥ ម៉ែត្រ ជំរៅ ០.៥០ ម៉ែត្រ (កន្លះម៉ែត្រ) ដំបូលប្រក់ស្លឹក ជញ្ជាំងបិតដីជុំវិញ។

I. **សំភារៈសំរាប់ធ្វើជីកំប៉ុស្តគោក** ៖

✹ ចប បង្គី កាំបិត ពូថៅ ឈើ ឬ ឫស្សី ស្លឹកប្រក់ដំបូល ខ្សែ (រោងផ្សំជី )

II. **វត្ថុធាតុដើម៖**

✹ ជីស្រស់ លាមកសត្វ កាកសំណល់ផ្ទះបាយ

✹ ស្លឹកឈើស្ងួត គល់ជញ្ជ្រាំង ដីបាតត្រពាំង ឬ ដីដំបូក

III. **របៀបធ្វើ៖**

ធ្វើទ្រុងមានដំបូលពីលើ ប្រើបង្គោលឬស្សី ដោយកំណត់យកផ្ទៃ ២ x ៣ ម៉ែត្រ ដោយចែកជាពីរផ្នែកសម្រាប់ធ្វើការប្រែត្រឡប់គំនរជី កន្លែងធ្វើរោងជីកំប៉ុស្តគួរធ្វើនៅកន្លែងជិតប្រភពទឹក តែជាកន្លែងដីទួលមិនលិចទឹកនៅរដូវវស្សា។

ស្រទាប់ទី១: ដាក់ស្លឹកឈើស្ងួត ឬចំបើង ខាងក្រោមកំរាស់ ១ តឹក



# ដំណាំម្រះ

ដំណាំម្រះ ម៉ូម៉ូឌីកា ចារ៉ាន់ទី (Momordica charantia) ស្ថិតនៅ ក្នុងគ្រួសារ គុកួប៊ីតាសៀ (Cucurbitaceae) វាជាដំណាំមួយប្រភេទ ដែលដុះ លូត លាស់ល្អនៅក្នុងអាកាសធាតុ តំបន់ត្រូពិច វាត្រូវបានគេស្គាល់ និង និយមដាំដុះជាងគេ នៅភូមិភាគអាស៊ី-អាគ្នេយ៍ ព្រោះវាផ្តល់អត្ថប្រយោជន៍ច្រើនយ៉ាងដល់អ្នកប្រើប្រាស់ ធ្វើជាបន្លែ និងបន្លែកែច្នៃ ដាក់កំប៉ុង ជាពិសេស ម្រះជាប្រភព វត្ថុធាតុដើមនៅក្នុងឧស្សាហកម្ម ផលិតឱសថ សំរាប់ទប់ស្កាត់ និងជួយព្យាបាល ជំងឺមហារីក ដំបៅថ្លើម ជាដើម ***(សូមមើលឧបសម្ព័ន្ធ៣)***។

នៅកម្ពុជា គេដាំម្រះជាដំណាំប្រចាំរដូវ តែនៅប្រទេសខ្លះ គេបានដាំវាជាដំណាំច្រើនឆ្នាំ។ ម្រះជាដំណាំមួយ ដែលធន់នឹងកំដៅបានល្អបង្គួរ គេអាចដាំដុះបានពេញមួយឆ្នាំ ប៉ុន្តែ វាក៏ជាដំណាំ ដែលងាយទទួលរងនូវការបំផ្លាញដោយសារដីសើមទឹកផងដែរ។ សីតុណ្ហភាពដែលល្អប្រសើរសម្រាប់ដំណាំម្រះ ដុះលូតលាស់គឺនៅចន្លោះចាប់ពី 20 ទៅ 35 អង្សាសេ វាអាចធន់នឹងសីតុណ្ហភាពទាបជាងគេ គឺរហូតដល់ 18អង្សាសេ។ ប្រសិន បើដាំដុះខុសរដូវកាល យើងនឹងប្រឈមមុខជាមួយនឹងបញ្ហាច្រើនប្រភេទដូចជា អាកាស ធាតុក្តៅខ្លាំង ភ្លៀងធ្លាក់ជោគជាំ និងរងការបំផ្លាញពីសត្វល្អិត និង ជំងឺច្រើនប្រភេទ។ ប្រភេទដីដែលសមស្របជាមួយដំណាំម្រះ គឺជាដីល្បាយមានជីជាតិល្អ និង មានកម្រិត pH ចន្លោះ 6.0-6.7 តែវាក៏អាចដុះលូតលាស់បាន នៅលើដីដែលមាន pH 8.0 បានដែរ។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម
© CFAP Cambodia 2024

## ១. បច្ចេកទេសដាំដុះ

### ១.១ .ការជ្រើសរើសពូជ

បច្ចុប្បន្នមានពូជម្រះ ច្រើនប្រភេទ ដែលគេកំពុងធ្វើការដាំដុះ នៅទូទាំង ប្រទេសកម្ពុជា តែនៅតំបន់ខ្លះ គេនិយមដាំពូជក្នុងស្រុក និង តំបន់ ខ្លះទៀត គេចូលចិត្តដាំពូជទំនើប ដែលផលិតចេញមកពីក្រុមហ៊ុន ដែលភាគ ច្រើនគឺជាពូជបង្កាត់ (F1) ដែលបាននាំចូល មកពីបរទេស ដូចជាពូជម្រះរបស់ក្រុមហ៊ុនពីប្រទេសវៀតណាម ប្រទេសថៃ និង ប្រទេសតៃវ៉ាន់ ដែលពូជទាំងនោះ សុទ្ធតែមានអត្រាដំណុះខ្ពស់ និង ទិន្នផលច្រើន ដូច្នេះ ការជ្រើសរើសពូជ គឺចាំបាច់ត្រូវគិតទៅលើតម្រូវការទីផ្សារ ដែលជា ចំណុច អាទិភាព ។





© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

# អត្ថប្រយោជន៍ជីធម្មជាតិ

### ផលប្រយោជន៍សំខាន់ៗ របស់ជីធម្មជាតិ

១. ជួយកែលំអរគុណភាពដី គឺជួយធ្វើឱ្យដីមានជីជាតិកាន់តែល្អប្រសើរឡើង និងមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ តាមតម្រូវការរបស់ដំណាំនិងរុក្ខជាតិគ្រប់ប្រភេទ។

២. ជួយធ្វើឱ្យដីមានសំណើមល្អ ងាយស្រួលសម្រាប់រក្សាទុក និងផ្គត់ផ្គង់ជាបណ្តើរៗទៅផ្តល់អោយរុក្ខជាតិបានយូរ

៣. ជួយធ្វើអោយដីធូរល្អ មានដង្ហើមខ្យល់ចេញចូល ធ្វើឱ្យរុក្ខជាតិអាចស្រូបយកអុកស៊ីសែន (O2) និងសារធាតុចិញ្ចឹមផ្សេងៗ ពីខ្យល់បានល្អ។

៤. ជួយសម្របសម្រួល pH អោយបានសមស្រប (ដីមានជាតិអាស៊ីដ-ដីជូរ ឬដីអាល់កាឡាំង)។

៥. ត្រូវប្រើកំបោរស ១0តោន ក្នុងមួយហិកតា។

៦. ជួយទប់ស្កាត់ដល់ការហូរច្រោះ សឹករិចរិល ដោយសារខ្យល់ ភ្លៀង និងជួយការពារកំដៅ ព្រះអាទិត្យ។



© CFAP Cambodia 2024

## ប្រភេទថ្នាំគីមីកសិកម្មសំរាប់កំចាត់សត្វល្អិតចង្រៃ

ថ្នាំ Actara, Pegasus និងថ្នាំរូស៊ីន អាចមានប្រសិទ្ធភាពសំរាប់គ្រប់គ្រង ពពួកចៃ រុយស និងពពួកដង្កូវនេះបាន តែត្រូវ ប្រើតាមកម្រិតណែនាំរបស់ស្លាកថ្នាំ។




ថ្នាំអាតារា




ថ្នាំប៉េហ្គាស៊ីស




ថ្នាំ ប៊ីធី (Bt) សំរាប់កំចាត់ដង្កូវយោលទោង



ថ្នាំរូស៊ីន



### ១.២. ការរៀបចំដីដាំម្រះ

- ភ្ជួរហាលដីអោយស្ងួត ហើយរាស់ប្រមូលយកស្មៅចេញ
- ភ្ជួររាស់យ៉ាងតិចឱ្យបាន ៣-៤ ដង
- ទទឹង ១,២ ម៉ែត្រ បណ្តោយទៅតាមស្ថានភាពដីជាក់ស្តែង
- ចន្លោះជួរ ៨០សង់ទីម៉ែត្រ ចន្លោះគុម្ព ៥០-៦០ សង់ទីម៉ែត្រ

រូបភាពទី៤៖ ការរៀបចំរងដាំម្រះ និងរបៀបចោះកៅស៊ូលើរង



### ២. របៀបបណ្តុះកូន

- សាបគ្រាប់នៅក្នុងកន្ទោងឬថាសបណ្តុះកូនឬសម្ភារក្នុងស្រុកអាចធ្វើជំនួសបាន
- ល្បាយដីបណ្តុះកូន ត្រូវដុតកំដៅសម្លាប់មេរោគ មុនពេលយកវាមកប្រើ
- ប្រើថ្នាំការពារជំងឺផ្សិត លាយជាមួយគ្រាប់ពូជ មុនពេលយកវាទៅបណ្តុះ
- កូនសំណាបអាចយកវាទៅដាំលើរងបានពេលវាបានអាយុ ១៥-២០ថ្ងៃ។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម
© CFAP Cambodia 2024

រូបភាពទី៥៖ ការលើងដីសំរាប់បណ្ដុះកូនដំណាំ



### ៣. របៀបដាំដុះ

- ដាំ ២ជួរ ក្នុងមួយរង ហើយចន្លោះគុម្ព 0.5m (ស្មើនឹងកន្លះម៉ែត្រ) ហើយដាំនៅតាមចំហៀងរង

- ចំនួនគុម្ពសរុប = 40 គុម្ពក្នុងមួយរង x 10 រង = 400 គុម្ព។

### ៤. ការប្រើប្រាស់ជី

ការប្រើប្រាស់ជីលើដំណាំម្រេះ គឺមានការប្រែប្រួល យោងទៅតាមប្រភេទដី និងប្រវត្តិនៃការដាំដុះដំណាំនៅលើដីនោះផងដែរ។ ខាងក្រោមនេះគឺជាតម្រូវការជីសំខាន់ៗដែលដំណាំម្រេះត្រូវការ និងពេលវេលាប្រើប្រាស់ ហើយបរិមាណ ពេលវេលាប្រែប្រួលទៅតាមតំបន់។ ការប្រើជី ដែលបានទទួលទិន្នផលល្អសំរាប់ដំណាំម្រេះ គឺ

- ប្រើជីលាមកសត្វ ឬ ជីកំប៉ុស្តក្នុងកម្រិត ៣០គក្រក្នុងមួយរង សំរាប់ ទ្រាប់បាត ហើយបរិមាណជីនេះ ដាក់នៅពេលដំណាលគ្នាជាមួយការប្រើកំបោរកសិកម្ម មុនពេលគ្របកៅស៊ូ។
-



## ឧបសម្ព័ន្ធ ៤

### ការប្រើប្រាស់ថ្នាំគីមីកសិកម្មសំរាប់កំចាត់សត្វល្អិតចង្រៃ

ការប្រើប្រាស់ថ្នាំគីមីកសិកម្មសម្រាប់កំចាត់សត្វល្អិតបំផ្លាញដំណាំ គឺជាវិធានការគីមីមួយដែលចាំបាច់ក្នុងករណីដែលដំណាំរងនូវការបំផ្លាញខ្លាំងប៉ុណ្ណោះ ពីពពួកសត្វល្អិតចង្រៃ។ ការប្រើប្រាស់ថ្នាំគីមីចាំបាច់ត្រូវពិនិត្យ និងអនុវត្តតាមស្លាកសញ្ញា ការណែនាំ នៅលើកញ្ចប់ថ្នាំ ដើម្បីសុវត្ថិភាពអ្នកប្រើប្រាស់ និងប្រើឱ្យចំគោលដៅ។

ដើម្បីឱ្យមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់ថ្នាំគីមីកសិកម្ម ចាំបាច់ត្រូវអនុវត្តដូចខាងក្រោម៖

- ពេលបាញ់ថ្នាំអ្នកត្រូវពាក់អាវ ពាក់ម៉ាស ស្រោមដៃ និងស្បែកជើងកវែង
- ពេលបាញ់ថ្នាំត្រូវពិនិត្យមើលទិសខ្យល់បក់
- មិនត្រូវបរិភោគចំណីអាហារពេលបាញ់ថ្នាំឡើយ
- លាងសំអាតខ្លួនប្រាណ និងសំលៀកបំពាក់ជាមួយសាប៊ូ ក្រោយ ពីការបាញ់ថ្នាំ
- កប់ ឬ ដុតសំបកថ្នាំដែលប្រើប្រាស់រួច
- រក្សាថ្នាំទុកនៅកន្លែងដែលមានសុវត្ថិភាព និងឱ្យផុតពីដៃក្មេង

**ចំណាំ៖**

ក្នុងករណីមានថ្នាំគីមីកសិកម្មចូលក្នុងភ្នែកអ្នក ចាំបាច់ត្រូវលាងជាមួយទឹកស្អាតជាមុនសិន រួចទៅកាន់មន្ទីរពេទ្យជាបន្ទាន់ ដើម្បីជួបជាមួយអ្នកជំនាញព្យាបាល។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

| | | | | | |
|---|---|---|---|---|---|
| 23 | ម៉ង់កាណែស | -- | -- | 0.214 mg | 9% |
| 24 | ផូស្វរ | 450.61 mg | -- | 38 mg | 6% |
| 25 | ស័ង្កសី | -- | -- | 0.24 mg | 2% |
| <u>Phyto-nutrients</u> | | | | | |
| 26 | ការ៉ូតែនបែតា | -- | -- | 379 µg | -- |
| 27 | ការ៉ូតែនអាល់ហ្វា | -- | -- | 69 µg | -- |
| 28 | លុយតេអ៊ីន | -- | -- | 640 µg | -- |



- ប្រើជីប្រភេទ 15-15-15 ក្នុងកម្រិត ១០ក្រាម/គុម្ព ដាក់បង្កប់បាត រណ្តៅ មុនពេលដាំ
- ជីបំប៉នលើកទី១ ដាក់នៅពេលពូនគល់ ឬពេលដាក់ទ្រើង ប្រើជី 15-15-15 ក្នុងកម្រិត ១០ក្រាម/គុម្ព ដាក់បង្កប់ក្នុងដីចំនួន២កន្លែង នៅក្បែរគុម្ពចំងាយ ១០សម ពីគល់របស់វា។
- ជីបំប៉នលើកទី២ ដាក់នៅក្រោយពេលប្រមូលផលលើកទី១ ប្រើជីអ៊ុយរ៉េ ក្នុងកម្រិត ១០ក្រាម/គុម្ព ដាក់បង្កប់ក្នុងដីចំនួន២កន្លែង នៅក្បែរគុម្ពចំងាយ ១០សម ពីគល់របស់វា។
- ជីបំប៉នលើកទី៣ ប្រើជី FDP ក្នុងកម្រិត១គ្រាប់/គុម្ព ដាក់បង្កប់ នៅក្នុងដី ក្បែរគុម្ពដំណាំ នៅក្រោយពេលដាក់លើកទី២ បានរយៈ ពេល ១០-១២ថ្ងៃ ។







© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

### ៥. របៀបធ្វើទ្រើង

នៅពេលដែលយើងឃើញម្រះបោះដៃតោងឡើងហើយ បើយើងពុំប្រញាប់ដាក់ទ្រើងអោយវាឡើងទេ គឺអាចធ្វើអោយដើមម្រះធ្លាក់ដូល ហើយវារនៅលើដី ប្រសិនបើក្នុងរដូវភ្លៀង អាចបង្ករអោយផ្លែរលួយស្អុយ និងមានជំងឺជាច្រើន។ សព្វថ្ងៃនេះគេនិយមប្រើចំណារ ដែលធ្វើអំពីសំណាញ់ជ័រ ព្រោះវាមានតម្លៃថោក មុនពេលវាយសំណាញ់ យើងត្រូវយកបង្គោល ដែលមានកំពស់ប្រវែង 2.5m មកដាំតាមបណ្តោយរង ចន្លោះពីបង្គោលមួយទៅបង្គោលមួយទៀតប្រវែង 2.5m ហើយរបៀបធ្វើទ្រើង គឺមានច្រើន បែប ដូចមានបញ្ជាក់ក្នុងរូបភាពខាងក្រោមស្រាប់។



ទ្រើងធ្វើពីសំណាញ់



ទ្រើងធ្វើពីឬស្សី

### ៦. ការថែទាំក្រោយពេលដាំ

### ៦.១. ការស្រោចស្រព

ម្រះជាប្រភេទដំណាំ ដែលមិនសូវធន់ជាមួយភាពរាំងស្ងួតទេ តែវាក៏មិនត្រូវការទឹកជោគជាំខ្លាំងពេកទេ ប្រសិនបើសំណើមដីសើមខ្លាំងពេក ឬ មានភ្លៀងជោគជាំ អាចធ្វើអោយម្រះមានស្លឹកក្រហម ស្រពោនងាប់ដើមតែម្តង។ នៅរដូវរំហើយ ការស្រោចស្រព



| | | | | | |
|---|---|---|---|---|---|
| 11 | វីតាមីន B2 | 0.40 mg | -- | 0.105 mg | 8% |
| 12 | វីតាមីន B1 | 0.26 mg | -- | 0.084 mg | 7% |
| 13 | វីតាមីន A | 24.59 IU | -- | 690 IU | 23% |
| 14 | វីតាមីន C | 100.71 mg | -- | 16.3 mg | 27% |
| 15 | វីតាមីន E | -- | -- | -- | -- |
| 16 | វីតាមីន K | -- | -- | 14.4 µg | 12% |
| **អេឡិចត្រូលីត** | | | | | |
| 17 | សូដ្យូម | -- | -- | 6 mg | 0.40% |
| 18 | ប៉ូតាស្យូម | -- | -- | 209 mg | 5.50% |
| **ជាតិខនិជ** | | | | | |
| 19 | កាល់ស្យូម | 216.96 mg | -- | 37 mg | 3.70% |
| 20 | ទង់ដែង | -- | -- | -- | -- |
| 21 | ដែក | 4.77 mg | -- | 1.04 mg | 13% |
| 22 | ម៉ាញ៉េស្យូម | -- | -- | 25 mg | 6% |



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម
© CFAP Cambodia 2024

| លរ. | បរិយាយ | គ្រាប់ |  | សណ្ដែកកួ |  |
|---|---|---|---|---|---|
|  |  | សារធាតុចិញ្ចឹម | (%) | សារធាតុចិញ្ចឹម | (%) |
| 1 | ថាមពល | 666.14 Kca | -- | 31 Kcal | 1.50% |
| 2 | កាបូណហ៊ីដ្រាត | 7.55 g | -- | 7.13 g | 5.50% |
| 3 | ប្រូតេអ៊ីន | 0.61 g | -- | 1.82 g | 3% |
| 4 | សារធាតុធ្វើឲធាត់ | 0.15 g | -- | 0.34 g | 1% |
| 5 | ខ្លាញ់Cholesterol | 0 g | -- | 0 mg | 0% |
| 6 | ជាតិសរសៃ | 7.09 g | -- | 3.4 g | 9% |
| **វីតាមីន** |  |  |  |  |  |
| 7 | វីតាមីន B9 | -- | -- | 37 μg | 9% |
| 8 | វីតាមីន B3 | 12.24 mg | -- | 0.752 mg | 5% |
| 9 | វីតាមីន B5 | -- | -- | 0.094 mg | 2% |
| 10 | វីតាមីន B6 | -- | -- | 0.074 mg | 5.50% |



ដោយបូមចង្អូរ (កូនប្រឡាយ) តាមចន្លោះរង គឺធ្វើឡើងក្នុងរវាង 7-10 ថ្ងៃម្តង។ នៅក្នុងរដូវភ្លៀង ប្រសិនបើមានភ្លៀងធ្លាក់ខ្លាំង ត្រូវបង្ហូរទឹកចេញពីថ្នាលជាបន្ទាន់ ការស្រោចស្រពដោយប្រព័ន្ធខ្សែប (Drip) គឺជាមធ្យោបាយមួយ ដែលសមស្រប នៅតំបន់ដែលមានបញ្ហាខ្វះខាតទឹក និង ជួយអោយម្រះ ដុះលូតលាស់ល្អធ្វើអោយដីធូរ មិនសូវដុះស្មៅ និងជួយអោយដីសំបូរខ្យល់ និងផ្តល់ទឹក តាមតម្រូវការរបស់ម្រះទៀតផង។

**៦.២. ការកាត់តែងមែក**

ដើម្បីអោយម្រះ ទទួលបាននូវទិន្នផលខ្ពស់ ចាំបាច់គេ ត្រូវធ្វើការ កាត់មែកដែលដុះចេញពីចំហៀង ដើមមេ ដែលជាមែកគ្មានប្រយោជន៍ ព្រោះមែកទាំងនោះ ពុំសូវសំបូរផ្កាញីទេ។ ការកាត់នេះ ជំរុញអោយម្រះមាន ផ្លែធំ វែងល្អ និងជួយកាត់បន្ថយសារធាតុដែលទៅចិញ្ចឹមមែក និងស្លឹក ដែលលូតលាស់គ្មានប្រយោជន៍ ខ្នែងដែលដុះចេញពីថ្នាំងផ្នែកខាងក្រោម ចំនួន៧-១០ថ្នាំង ដំបូង មិនគួរទុកអោយវាដុះលូតលាស់ទេ ត្រូវកាត់វាចេញ និង កាត់ត្រួយដើមមេចេញ នៅពេលដែលវា វារឡើងទ្រើងបានខ្ពស់ ដើម្បីជួយអោយមែកចំហៀង ផ្នែកខាងលើ លូតលាស់បានល្អ និងកាន់ផ្លែបានច្រើនដូចៗគ្នា។





© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## ៧.សត្វល្អិត និងជំងឺលើដំណាំម្រះ

### ៧.១. សត្វល្អិតចង្រៃ

រុយទិចផ្លែ គឺជាបញ្ហាចំបងមួយ លើដំណាំម្រះ ហើយយើងមានការលំបាក ក្នុងការគ្រប់គ្រង ព្រោះវាពងដាក់ក្នុងផ្លែម្រះ ម្យ៉ាងទៀតក្នុងដំណាក់កាលនេះយើងមិនអាចប្រើថ្នាំបានទេ។ រុយនេះ បំផ្លាញភាគច្រើន លើផ្លែម្រះ និង ផ្លែត្រសក់ ដោយពងដាក់បញ្ចូលទៅក្នុងផ្លែជាចង្កោមៗ ប្រហែល១២ពង។ ដង្កូវរបស់វាមានរយៈពេលពី៥-៧ថ្ងៃ ហើយវារស់នៅក្នុងផ្លែម្រះ ភាពជាឌឹកឌឿរបស់វា ជាទូទៅនៅក្នុងដី ឬ ក្នុងផ្លែ ម្រះ ប្រហែល ១០ថ្ងៃបន្តទៀត ទើបញាស់ជាមេចំណាស់។ ដើម្បីការពារ យើងអាចប្រើក្រដាស ឬ ថង់ប្លាស្ទិច មករុំផ្លែម្រះនៅអនុវត្តតាមវិធីនេះបានទាំងស្រុងទេ ដូច្នេះ យើងអាចប្រើអន្ទាក់អរម៉ូន ដើម្បីចាប់យកមេចំណាស់ មិនអោយវាបន្តពងដាក់ផ្លែម្រះ។ ម៉្យាងទៀត គេអាចប្រើថ្នាំសំរាប់បណ្ដេញមេចំណាស់ មិនអោយវាហើរចូលក្នុងចំការម្រះបាន។



ស្រាំងអុចផ្លែម្រះ







| | | | | | |
|---|---|---|---|---|---|
| 23 | ម៉ង់កាណែស | 0.250 mg | 11% | 0.079 mg | 3.50% |
| 24 | ផូស្វរ | -- | -- | 24 mg | 3% |
| 25 | ស័ង្កសី | 0.16 mg | 1% | 0.20 mg | 2% |
| **Phyto-nutrients** | | | | | |
| 26 | ការ៉ូតែនបែតា | 190 µg | -- | 45 µg | -- |
| 27 | ការ៉ូតែនអាល់ហ្វា | 185 µg | -- | 26 µg | -- |
| 28 | លុយតេអ៊ីន | 170 µg | -- | 23 µg | -- |



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

| | | | | | |
|---|---|---|---|---|---|
| 11 | វីតាមីន B2 | 0.037 mg | 3% | 0.033 mg | 3% |
| 12 | វីតាមីន B1 | 0.039 mg | 3% | 0.027 mg | 2% |
| 13 | វីតាមីន A | 27 IU | 1% | 105 IU | 3.50% |
| 14 | វីតាមីន C | 2.2 mg | 3.50% | 2.8 mg | 4.50% |
| 15 | វីតាមីន E | 0.30 mg | 2% | 0.03 mg | 0% |
| 16 | វីតាមីន K | 3.5 µg | 3% | 16.4 µg | 13.60% |
| **អេឡិចត្រូលីត** | | | | | |
| 17 | សូដ្យូម | 2 mg | 0% | 2 mg | 0% |
| 18 | ប៉ូតាស្យូម | 230 mg | 5% | 147 mg | 3% |
| **ជាតិខនិជ** | | | | | |
| 19 | កាល់ស្យូម | 9 mg | 1% | 16 mg | 1.60% |
| 20 | ទង់ដែង | 0.082 mg | 9% | -- | -- |
| 21 | ដែក | 0.24 mg | 3% | 0.28 mg | 3.50% |
| 22 | ម៉ាញ៉េស្យូម | 14 mg | 3.50% | 13 mg | 3% |



## ៧.២. ការគ្រប់គ្រងជំងឺ និងសត្វល្អិតចង្រៃ ៖

### *៧.២.១ ការគ្រប់គ្រងសត្វល្អិតចង្រៃ*

*ក. អណ្តើកមាសកខ្ចីស៊ីស្លឹកម្រះ*

**វិធានការគ្រប់គ្រង នឹងកំចាត់**

- សំអាតស្មៅនៅក្នុងចំការ
- ភ្ជួរដីហាលអោយស្ងួតល្អ(ពី៥-៧ថ្ងៃ)
- ដាំដំណាំឆ្លាស់ រឺ ប្រើថ្នាំកសិកម្មផ្សំពីរុក្ខជាតិ
- ករណីធ្ងន់ធ្ងរប្រើថ្នាំគីមីកសិកម្ម

+ Dragon 20 - 25 សេសេ/១៨ លីត្រទឹក

+ Abamectin(អាបាម៉ិចទីន) 20 - 25 សេសេ/១៨ លីត្រទឹក

បាញ់ចន្លោះពេល ៧ - ១០ថ្ងៃម្តង រយៈពេល ២-៣ដង បាញ់អោយសព្វកន្លែងចំគ្រួយខ្ចីៗ (បាញ់នៅពេលព្រឹក) បញ្ឈប់ការប្រើថ្នាំមុនពេលប្រមូលផល ១០ - ១៥ថ្ងៃ ។

*ខ. ទ្រីបជញ្ជក់ស្លឹក*

**វិធានការគ្រប់គ្រង នឹងកំចាត់**

- សំអាតស្មៅនៅក្នុងចំការ
- ប្រើថ្នាំពុលផ្សំពីរុក្ខជាតិ
- គ្របកៅស៊ូប្លាស្ទិកលើរង ដកដើមដែលរលួយចោល រក្សារដីអោយសើម
- ករណីធ្ងន់ធ្ងរប្រើថ្នាំពុលគីមី

+ Abamectin 20 - 25 សេសេ/១៨ លីត្រទឹក

បាញ់ចន្លោះពេល ៧ - ១០ថ្ងៃម្តង រយៈពេល ២ - ៣ ដង បាញ់អោយសព្វកន្លែងចំគ្រួយខ្ចីៗ (បាញ់នៅពេលព្រឹក) បញ្ឈប់ការប្រើថ្នាំមុនពេលប្រមូលផល ១០ - ១៥ថ្ងៃ ។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

- ប្រើថ្នាំអាកតារ៉ា (Actara) ឬថ្នាំអាបាមិចទីន ទៅតាមកំរិតណែនាំរបស់ស្លាកថ្នាំ

*គ. ចៃខ្មៅ*

**វិធានការគ្រប់គ្រង នឹងកំចាត់**

- សំអាតស្មៅនៅក្នុងចំការ
- ដាំដំណាំមានក្លិនលាយជាមួយម្រេះ
- ប្រើថ្នាំពុលផ្សំពីរុក្ខជាតិ
- ករណីធ្ងន់ធ្ងរប្រើថ្នាំពុលគីមី

+ Supracide 10 - 25 សេសេ/១៨ លីត្រទឹក

+ Abamectin 20 - 25 សេសេ/១៨ លីត្រទឹក

បាញ់ចន្លោះពេល ៧ - ១០ថ្ងៃម្តង រយៈពេល ២ - ៣ ដង បាញ់អោយសព្វកន្លែងចំគ្រួយខ្ចីៗ (បាញ់នៅពេលព្រឹក) បញ្ឈប់ការប្រើថ្នាំមុនពេលប្រមូលផល ១០ - ១៥ថ្ងៃ ។

*ឃ. ស្រាំងទិច ឬ រុយអុចផ្លែ*

**វិធានការគ្រប់គ្រង នឹងកំចាត់**

- សំអាតស្មៅនៅក្នុងចំការ
- ប្រមូលនឹងបេះយកផ្លែដែលបំផ្លាញចោល
- ប្រើថ្នាំពុលផ្សំពីរុក្ខជាតិ ***(សូមមើលឧបសម្ព័ន្ធ៥)***



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

**<u>ឧបសម្ព័ន្ធ៣</u>**

**តារាងវិភាគសារធាតុចិញ្ចឹមនៅក្នុងបន្លែ ១០០ក្រាម**

| លរ. | បរិយាយ | ម្រេះ | | ត្រសក់ | |
|---|---|---|---|---|---|
| | | **សារធាតុចិញ្ចឹម** | **(%)** | **សារធាតុចិញ្ចឹម** | **(%)** |
| 1 | ថាមពល | 24 Kcal | 1% | 15 Kcal | <1% |
| 2 | កាបូហ៊ីដ្រាត | 5.7 g | 4% | 3.63 g | 3% |
| 3 | ប្រូតេអ៊ីន | 1 g | 2% | 0.65 g | 1% |
| 4 | សារធាតុធ្វើឱ្យធាត់ | 0.19 g | 1% | 0.11 g | 0.50% |
| 5 | ខ្លាញ់ Cholesterol | 0 mg | 0% | 0 mg | 0% |
| 6 | ជាតិសរសៃ | 3.40 g | 9% | 0.5 g | 1% |
| **<u>វីតាមីន</u>** | | | | | |
| 7 | វីតាមីន B9 | 22 µg | 5.50% | 7 µg | 2% |
| 8 | វីតាមីន B3 | 0.649 mg | 4% | 0.098 mg | <1% |
| 9 | វីតាមីន B5 | 0.281 mg | 6% | 0.259 mg | 5% |
| 10 | វីតាមីន B6 | 0.084 mg | 6.50% | 0.040 mg | 3% |



© CFAP Cambodia 2024



ចៃខ្មៅ



ចៃសបៃតង



ស្រឹងសណ្ដែកពណ៌បៃតង



ដង្កូវស៊ីផ្កា និង ស៊ីផ្លែ



ដង្កូវឃោលទោង



ដង្កូវស៊ីបណ្ដូល



## ៧.២.២ ជំងឺលើដំណាំ

### ក. ជម្ងឺស្រពោនដើម

**វិធានការគ្រប់គ្រង នឹងកំចាត់**

យើងអាចការពារនឹងកំចាត់ជំងឺនេះបានដោយបណ្ដុះកូននៅក្នុងកន្ទោងដែលយើងបានសម្លាប់មេរោគនៅក្នុងដី។ ប្រសិនបើ វាធ្វើការបំផ្លាញធ្ងន់ធ្ងរ យើងអាចប្រើថ្នាំមេតាក់ស៊ីល (Methaxyl) ឬថ្នាំ ហ្វូសេទីល (Fosetyl-Al) មកបាញ់ ការពារនៅលើស្លឹក នឹងនៅលើដីគឺអាចកាត់បន្ថយជំងឺនេះ ។

- ករណីធ្ងន់ធ្ងរប្រើថ្នាំពុលគីមី

+ Tung Grerin 50EC 10 - 25 សេសេ/១៨ លីត្រទឹក

+ Abamectin 20 - 25 សេសេ/១៨ លីត្រទឹក

បាញ់ចន្លោះពេល ៧ - ១០ថ្ងៃម្ដង រយៈពេល ២ - ៣ ដង បាញ់អោយសព្វកន្លែងចំត្រួយខ្ចីៗ (បាញ់នៅពេលព្រឹក) បញ្ឈប់ការប្រើថ្នាំមុនពេលប្រមូលផល ១០ - ១៥ថ្ងៃ ។

### ខ. ជម្ងឺផ្សិតទុំលឿងស្លឹក

**វិធានការគ្រប់គ្រង នឹងកំចាត់**

- ជ្រើសរើសពូជធន់ និងដាំដំណាំឆ្លាស់
- បង្កើនការស្រោចទឹកនៅពេលអាកាសធាតុក្ដៅ
- ប្រើថ្នាំពុលផ្សំពីរុក្ខជាតិ
- ករណីធ្ងន់ធ្ងរប្រើថ្នាំពុលគីមី



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

+ Ridomy 30 - 40 ក្រាម/១៨ លីត្រទឹក

+ Apine 2 កញ្ចប់ 20 ក្រាម/១៨ លីត្រទឹក

+ Danonil 30 - 40 ក្រាម/១៨ លីត្រទឹក

បាញ់ចន្លោះពេល ៧ថ្ងៃម្តង រយៈពេល ២ - ៣ ដង បាញ់អោយសព្វកន្លែងចំត្រួយខ្ចីៗ (បាញ់នៅពេលព្រឹក) បញ្ឈប់ការប្រើថ្នាំមុនពេលប្រមូលផល ៧-១០ ថ្ងៃ ។

### គ. ជម្ងឺផ្សិតឃ្លង់ស្លឹក ឬ ផ្លែ

**វិធានការគ្រប់គ្រង នឹងកំចាត់**

- ជ្រើសរើសពូជធន់ គ្រាប់ដែលមានថ្នាំការពារផ្សិត សំអាតស្មៅនៅក្នុងចំការ
- ប្រើថ្នាំពុលផ្សំពីរុក្ខជាតិ
- ករណីធ្ងន់ធ្ងរប្រើថ្នាំពុលគីមី

+ Chlorothalonil 30 - 40 ក្រាម/១៨ លីត្រទឹក

+ Thiophenate methyl 30 - 40 ក្រាម/១៨ លីត្រទឹក

+ Mancozeb 30 - 40 ក្រាម/១៨ លីត្រទឹក

បាញ់ចន្លោះពេល ៧ ថ្ងៃម្តង រយៈពេល ២ - ៣ ដង បាញ់អោយសព្វកន្លែងចំត្រួយខ្ចីៗ (បាញ់នៅពេលព្រឹក) បញ្ឈប់ការប្រើថ្នាំមុនពេលប្រមូលផល ៧-១០ ថ្ងៃ ។

### ឃ. ជម្ងឺស្រពោនដើម (ពុកឫស)

**វិធានការគ្រប់គ្រង នឹងកំចាត់**

- ជ្រើសរើសពូជធន់ ដាំដំណាំឆ្លាស់
- លើករងអោយបានខ្ពស់ៗហើយរងមានគ្របកៅស៊ូប្លាស្ទិច
- ប្រើថ្នាំពុលផ្សំពីរុក្ខជាតិ



## ឧបសម្ព័ន្ធ២

## សត្វល្អិតចង្រៃនៅក្នុងចំការ

យើងចង់ឱ្យសួនច្បាររបស់យើងល្អវាមិនមែនជាការងាយស្រួលនោះទេ។



**Aphids** ជាពពួកសត្វល្អិតដែលខ្លួនរបស់វាទន់។ វាស៊ីរុក្ខរសនៅក្នុងពន្លករុក្ខជាតិ ស្លឹក ក្រពុំផ្កា និងផ្កា ។



**ចៃ** ខ្លួនទន់គ្របដណ្តប់ដោយក្រមួនពណ៌ស ពណ៌ត្នោត និងពណ៌ប្រផេះ វាមានទំហំតូចក្រៃលែង ហើយវាស៊ីរុក្ខរស ។



**ពពួកអណ្តើកមាស** កខ្ចីមានអុច១២ចំណុច និងមួយទៀតមានអុច២៨ចំណុច វាជាពពួកសត្វល្អិតចង្រៃ



**រុយ** ទិចផ្លែវាបំផ្លាញដំណាំអំបូរត្រសក់ ម្រះ ត្រសក់។ វាមិនមែនពពួកស្រាំងទេ តែកសិករភាគច្រើនហៅថាស្រាំងទិចផ្លែ ។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024



**Dragonflies កន្ទុំរុយ** ពពួកវាមានជាង ៨០ ប្រភេទនៃកន្ទុំរុយគេអាចកំណត់ពពួកវាបានដោយមានខ្លួនវែង មានភ្នែកធំមានស្លាបថ្លាឆ្វង់៤។ ពណ៌របស់វាមានការប្រែប្រួលតាមទំហំ ហើយកូនញាស់គេសង្កេតឃើញនៅក្នុងទឹក។ ពពួកវាស៊ីមូស ពពួកសត្វល្អិត ដែលមកជញ្ជក់រុក្ខរស និងសត្វល្អិតផ្សេងៗទៀត



**Honeybees សត្វឃ្មុំ** គឺមានប្រយោជន៍ក្នុងដំណើរលំអងផ្កាអោយនៃរុក្ខជាតិជាច្រើន។ វាពេញវ័យមានទំហំ2/3 inch វាមានរោមទន់ វាមានពណ៌មាសលាយពណ៌ខ្មៅ ខ្លួនឆ្នូត ហើយស្លាបថ្លាឆ្វង។ សត្វឃ្មុំគេអាចសម្គាល់វាចូលចិត្តលំអងផ្កាពណ៌លឿង ពពួកវាចាប់យកលំអងដោយជើងរបស់វា ការលូតលាស់ផ្កាត្រូវបានសត្វឃ្មុំជួយជំរុញ។



## ៨. ការប្រមូលផល

ការប្រមូលផលពូជម្រះ អាស្រ័យទៅតាមពូជនីមួយៗ ជា ទូទៅ គេអាចប្រមូលផលម្រះ បាននៅពេលគេឃើញ ផ្លែរបស់វាមានក្រឡារីក ផ្លែធំស្មើ ពណ៌បៃតងស្រស់ និងរលោង។ គេអាចប្រមូលផលបានក្នុងរយៈពេលយូរ ទិន្នផលជាមធ្យមពី ១៥-១៨ តោន/ហ.ត ចំពោះពូជប្រពៃណី និង ពី ២៥-៥០ តោន/ហ.ត ចំពោះពូជនាំចូល។ ការប្រមូលផល គេច្រើនធ្វើឡើងនៅពេលព្រឹក នៅចន្លោះពីម៉ោង ៧ព្រឹក រហូតដល់ ម៉ោង១០ព្រឹក និងនៅពេលល្ងាចត្រជាក់។ គេប្រមូលផលរៀងរាល់ថ្ងៃ ឬ ពីរថ្ងៃម្តងដោយប្រើកន្ត្រៃ ឬកាំបិតមុតកាត់ទងរួចយកផ្លែម្រះទៅតំរៀបដាក់ក្នុង ខេង ឬកញ្ជើ ដោយធ្វើចំណាត់ថ្នាក់ផ្លែម្រះ ជា ៣ប្រភេទគឺ ប្រភេទលេខ១ ផ្លែធំវែង ប្រភេទលេខ២ ផ្លែមធ្យម និងប្រភេទលេខ៣ផ្លែតូច។ ផ្លែម្រះមិនអាចទុកយូរថ្ងៃទេ ប្រសិនបើ នៅលក្ខខណ្ឌធម្មតា គេអាចរក្សារទុកបាន៣-៤ថ្ងៃ ដូចនេះ បន្ទាប់ពីប្រមូលផលរួចត្រូវប្រញាប់យកទៅលក់នៅទីផ្សារ។







© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## ៩. ការតាមដានស្រែពិសោធន៍ និងប្រមូលទិន្នន័យ:

### ៩.១. ទិន្នន័យរបស់ដំណាំដែលត្រូវប្រមូលរួមមាន

- ឈ្មោះដំណាំ និងប្រភពពូជ - ផ្ទៃដីដាំដុះសរុប
- ថ្ងៃ.ខែ.ឆ្នាំ បណ្ដុះនិងដាំកូនដំណាំ
- ចំនួនគុម្ពដំណាំ ដោយរាប់ក្នុងដំណាក់កាលប្រមូលផលលើកដំបូង
- ថ្ងៃ.ខែ.ឆ្នាំដាក់ជីបំប៉ន និងបរិមាណដែលប្រើ
- ទិន្នផល ប្រាក់ចំណូល និងថ្ងៃ.ខែ.ឆ្នាំ ដែលបានប្រមូលផលក្នុងមួយលើកៗ
- វិធីសាស្ត្រស្រោចស្រព
- ប្រភេទសត្វល្អិត និងជំងឺដែលកើតមានច្រើនជាងគេ

### ៩.២. ទិន្នន័យផលិតកម្ម

- កត់ត្រារាល់ការចំណាយលើសម្ភារផលិតកម្មដោយរាយមុខចំណាយ និងតម្លៃសរុបសម្ភារនីមួយៗ ដែលបានទិញសំរាប់ដំណើរការផលិតកម្ម។
- តម្លៃប្រតិបត្តិនៅលើទីផ្សារ ដូចជាដឹកជញ្ជូន វេចខ្ចប់ ពន្ធលក់ដូរជាដើម។
- តម្លៃពលកម្ម ឧទាហរណ៍ ជួលពលកម្ម រៀបចំដី បាញ់ថ្នាំ....។ល។





**Hover Flies** វាពេញវ័យរាងដូចឃ្មុំតូចពោះឆ្នូត មានចំណុចប្រផេះនៅលើក្បាល ផ្កាហើរទៅជួបផ្កាមួយទៀតដើម្បីបង្កាត់ជាមួយលំអង និង ទឹកដមផ្កា កូនញាស់ស៊ីពពួកសត្វល្អិតជញ្ជក់រុក្ខរស កន្លែងចង្អៀត ដែលសត្វចង្រៃមិនអាច ទៅដល់ហើយវាជាសត្វពិសេស ដែលមានប្រយោជន៍ វាជាសត្វមានប្រយោជន៍សកម្មជាងគេ វាបាននាំលំអងទៅលើទងផ្កាដើម្បីអោយផ្លែរីកធំនិងទទួលបានទិន្នផលខ្ពស់ជាងមុន។



**Spiders ពីងពាង** សត្វពីងពាងទាំងអស់វាចិញ្ចឹមជីវិតដោយសត្វល្អិត ហើយវាមានសារៈសំខាន់ក្នុងការការពារកត្តាផ្សេងៗ។ ជាធម្មតាសត្វពីងពាងគេឃើញវានៅក្នុងសួនច្បារ ហើយពួកវាគ្មានពិស។ ដើមឈើធំនិងគំនរចំបើងជាជម្រកនិងធ្វើឱ្យចំនួនពីងពាងកើនឡើងយ៉ាងលឿននៅក្នុងសួនបន្លែ ។



**Tachini Flies រុយខៀវ** ទោះបីជាយើងឃើញ វាហាក់ដូចជារុយនៅតាមផ្ទះក៏ដោយរុយខៀវវាមានសារៈសំខាន់ណាស់ វាជាសត្រូវនៃដង្កូវកាត់ស្លឹក ដង្កូវមេអំបៅ។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## *ឧបសម្ព័ន្ធ ១ សត្វល្អិតមានប្រយោជន៍នៅក្នុងចំការ*

ជម្រើសមួយដ៏ល្អដើម្បីការពារសួនដំណាំគឺការប្រើសត្រូវធម្មជាតិ។ ការដាំរុក្ខជាតិមានលំអង និងទឹកដមផ្កា គឺបានផ្តល់ប្រយោជន៍ដល់សត្វល្អិតមានប្រយោជន៍ ដាំសួនសរីរាង្គជាគោលការណ៍គ្រឹះ ហើយជាវិធីមួយទៅអនាគតធ្វើអោយបរិស្ថានវិទ្យានានាកើនឡើងនៃសួនរបស់អ្នក។



Ladybugs អណ្តើកមាស មានរាងមូល ខ្លួនរបស់វាមានពណ៌ទឹកក្រូច វាជាសត្វល្អិតមួយក្នុងចំណោមសត្វល្អិតជាង ៤០០ ប្រភេទ ខ្លួនរាងមូល ដែលមាននៅអាមេរិចខាងជើង។ អណ្តើកមាស ភាគច្រើនពេញវ័យនិងមានវដ្តជីវិតពេញលេញ ហើយវាស៊ីពពួកសត្វល្អិតដែលមកជញ្ជក់រុក្ខរស និងសត្វល្អិតដែលមានខ្លួនទន់ៗ អណ្តើកមាសពេញវ័យវាចូលចិត្តទឹកដម និងលំអងផ្កា ពួកវាត្រូវតែស៊ីមុនពេលវាបន្តពូជ។



Lacewings មានពណ៌បៃតងស្រាល ឬពណ៌ត្នោត Lacewings ពេញវ័យមានលក្ខណៈសំគាល់ដូចជា រាងធំ ស្លាបរាងសរសៃ វាស៊ីទឹកដមផ្កា ។ វាមានវដ្តជីវិតពេញលេញ ទោះជាយ៉ាងណាក៏ដោយ វាជាសត្វ predators (អ្នកជញ្ជក់ឈាម) វាស៊ីពពួកសត្វល្អិតដែលមកជញ្ជក់រុក្ខរស thrips ចៃ មេអំបៅតូចៗ និងពពួកសត្វល្អិតចង្រៃតូចៗ ។



# ដំណាំត្រឡាច

- ត្រឡាច ដែលអាចទទួលផលដំបូងក្នុងរយៈពេលពី ៥៥ - ៦០ថ្ងៃ ក្រោយការដាំដុះ។

*ចំពោះការរៀបចំដី និងការធ្វើរងគឺធ្វើដូចដាំដំណាំ ត្រសក់ដែរ*

**១. របៀបបណ្តុះកូន**

- សាបគ្រាប់នៅក្នុងកន្ទោង ឬថាសបណ្តុះកូន ឬសម្ភារក្នុងស្រុកអាចជំនួសបាន
- ល្បាយដីបណ្តុះកូន ត្រូវដុតកំដៅសម្លាប់មេរោគ មុនពេលយកវាមកប្រើ
- ប្រើថ្នាំការពារជំងឺផ្សិត លាយជាមួយគ្រាប់ពូជ មុនពេលយកវាទៅបណ្តុះ
- កូនសំណាបអាចយកវាទៅដាំលើរងបានពេលវាបានអាយុ ១៥ - ២០ថ្ងៃ។

**២. របៀបដាំដុះ**

- ដាំ ២ជួរ ក្នុងមួយរង ហើយចន្លោះគុម្ព 0.5m (ស្មើនឹងកន្លះម៉ែត្រ) ហើយដាំនៅតាមចំហៀងរង

រូបភាពទី១៤៖ ការធ្វើទ្រើងត្រឡាច





© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

### ៣. ការប្រើប្រាស់ជីបំប៉នក្រោយដាំ

- **<u>ជីបំប៉នលើកទី១</u> ប្រើជី** FDP (ជីគ្រាប់ធំ) ចំនួន១គ្រាប់ ក្នុងមួយគុម្ព ដាក់បង្កប់ក្នុងដីជំរៅ និងចំងាយ 10cm ពីគុម្ពដំណាំ ហើយដាក់នៅពេលពូនគល់ដំបូង ឬ ពេលដាក់ទ្រើង។

- **<u>ជីបំប៉នលើកទី២</u> ប្រើជី** FDP (ជីគ្រាប់ធំ) ចំនួន១គ្រាប់ ក្នុងមួយគុម្ព ដាក់បង្កប់ក្នុងដីជំរៅ និងចំងាយ 10cm (ស្មើនឹង១តឹក) ពីគុម្ពដំណាំ ហើយដាក់នៅពេលត្រឡាចចេញផ្កាដំបូង។

- **<u>ជីបំប៉នលើកទី៣</u> ប្រើជីអ៊ុយរ៉េ ក្នុងកម្រិត ៣ក្រាមក្នុងមួយគុម្ព ដាក់បង្កប់ ក្នុងដីក្បែរគុម្ពដំណាំ ក្រោយពេលប្រមូលផលលើកដំបូងរួច។**

រូបភាពទី១៤៖ ការដាក់ជីបំប៉ន





ដើម្បីងាយស្រួល ក្នុងការធ្វើចំណាត់ថ្នាក់ ក្នុងពេលបេះផ្លែ ការធ្វើចំណាត់ថ្នាក់ គឺជាមធ្យោបាយមួយសម្រាប់បង្កើនតម្លៃបន្ថែមទៅលើផលិតផល និង ជាវិធីទាក់ទាញអ្នកទិញអោយចង់ទិញផលិតផលរបស់យើងផង។ ក្នុងការធ្វើចំណាត់ថ្នាក់ យើងអាចចែកជា ៣ប្រភេទគឺ

- ✓ ប្រភេទទី១៖ ជាផ្លែដែលខ្ចី មូល រលោង ត្រង់ល្អ ហើយក្លូររបស់វា មានប្រវែងចាប់ពី ៤៥ស.ម ឡើងទៅ និងគ្មានស្នាមបំផ្លាញនៅលើផ្លែ។
- ✓ ប្រភេទទី២៖ ជាផ្លែដែលមិនចាស់ជ្រុលពេក អាចយកវាទៅប្រើប្រាស់បាន ហើយក្លូររបស់វាមានប្រវែងមិនលើសពី ៤៥ស.ម ។
- ✓ ប្រភេទទី៣៖ ជាផ្លែដែលសល់ពីការចាត់ថ្នាក់ទាំង២ប្រភេទខាងលើ។ យើងមិនអាចយកទៅលក់ឱ្យអ្នកបរិភោគបានទេ តែអាចយក មក ធ្វើជាចំណីសត្វបាន។

ក្រោយពេលធ្វើចំណាត់ថ្នាក់រួច ត្រូវចងវាជាបាច់តូចៗ ដើម្បីអោយអ្នកទិញ ងាយស្រួលត្រួតពិនិត្យ និង មានចិត្តចង់ទិញផលិតផល។ ដើម្បីកុំអោយសណ្តែកស្រកទំងន់ដោយសារការបាត់បង់ជាតិទឹកចេញពីផ្លែ យើងត្រូវរក្សាវាទុកនៅកន្លែង ដែលមានសីតុណ្ហភាពត្រជាក់ ដោយយកវាមកដាក់តំរៀបជាគំនរតូចៗល្មម នៅលើកំរាលរាបស្មើ ហើយយកកន្សែងដែលជក់ទឹកល្អទៅជ្រលក់ទឹកអោយសើមរួចយកមកគ្របពីលើគំនរសណ្តែកនីមួយៗ ដើម្បីការពារវំហួតចំហាយទឹកចេញពីផ្លែសណ្តែក។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## ៨.ការប្រមូលផលសណ្តែកទ្រើង

ក្រោយពេលសណ្តែកទ្រើង បានអាយុ៥០ ទៅ៦០ថ្ងៃ យើងអាចប្រមូលផល លើកទីមួយបាន សំរាប់ការប្រមូលផលជាបន្លែស្រស់អាចធ្វើឡើងនៅពេលដែលផ្លែសណ្តែក ស្ថិតក្នុងដំណាក់កាលខ្ចី មិនទាន់មានគ្រាប់ពេញលេញ ហើយក្លូររបស់វាស្រឡូនល្អ មិនមានស្នាមកំពក គ្រាប់មានលក្ខណៈដូចជាខ្សែមួយសសៃ។ ពេលអនុវត្តការប្រមូលផល យើងត្រូវប្រលេះយកផ្លែចេញពីទងរបស់វាម្តងមួយៗ យកល្អយើងគួរប្រើកាំបិត ឬ កន្ត្រៃសំរាប់កាត់ផ្លែចេញពីទង។ ប្រសិនបើយើងបេះផ្លែដោយបន្សល់ទុកសណ្តង់ផ្លែ និង ផ្នែកខ្លះនៃផ្លែឱ្យនៅជាប់ជាមួយទង ផ្កា វានឹងធ្វើអោយសណ្តែកពន្យាពេលចេញផ្កានៅពេលបន្ទាប់។ ត្រូវបេះផ្លែដោយថ្នមដៃ ដើម្បីជៀសវាងការប៉ះទង្គិចខ្លាំងលើចញ្ចុំផ្កា ឬ រមួលទងផ្កា។

ដើម្បីងាយស្រួល ក្នុងការធ្វើចំណាត់ថ្នាក់ ក្នុងពេលបេះផ្លែ យើងត្រូវចងវា ជាដុំៗប៉ុនមួយក្តាប់ដៃដោយ ខ្សែចំណងផ្សេងៗ ដែល អាចរកបាន។ យើងត្រូវប្រមូលផលនៅពេលល្ងាចត្រជាក់ ឬ មុនពេលថ្ងៃលិច រាល់ការបេះមួយលើកៗ ត្រូវបេះទាំងផ្លែដែលចាស់ជ្រុល ឬ ផ្លែដែលមិនបានការចេញពីចំការអោយអស់ ព្រោះវាក៏ជាប្រភព ចំលងជំងឺផ្សេងៗ មកលើផ្លែជំនាន់ក្រោយ ជាពិសេសជំងឺផ្សិត។ ប្រសិនបើយើងដាំដុះវា ត្រឹមត្រូវតាមបច្ចេកទេស និងថែទាំបានល្អ នោះសណ្តែកទ្រើងអាចផ្តល់ផលចាប់ពី ១៨ ទៅ ២២ តោន/ហ.ត។



## ៤. ការគ្រប់គ្រងជំងឺ និងសត្វល្អិតចង្រៃ

### *៤.១ ការគ្រប់គ្រងសត្វល្អិតចង្រៃ*

*ក. រុយស*

**វិធានការគ្រប់គ្រង និងកំចាត់**

- ប្រើបន្ទះប្លាស្ទិចពណ៌លឿង ធ្វើអន្ទាក់សម្រាប់ទាក់ទាញមេចំណាស់ដោយមានលាបថ្នាំឬប្រេងស្អិតៗ
- ប្រើថ្នាំពុលផ្សំពីរុក្ខជាតិស្តៅមកបាញ់លើត្រឡាច នៅក្នុងដំណាក់កាលពងរបស់វាមិនទាន់ញាស់
- ប្រើថ្នាំអាកតារ៉ា (Actara) ឬ ថ្នាំអាបាមិចទីនទៅតាមកំរិតណែនាំរបស់ស្លាកថ្នាំ

*ខ. ចៃបៃតង និងចៃក្រហម*

**វិធានការគ្រប់គ្រង និងកំចាត់**

- ប្រើប្រាស់ថ្នាំពុលដែលផ្សំពីរុក្ខជាតិលាយជាមួយទឹក ហើយបាញ់រៀងរាល់ ១ សប្តាហ៍ម្តង ដើម្បីការពារការបំផ្លាញ ។

### *៤.២ ជំងឺលើដំណាំ*

*ក. ជម្ងឺស្រពោនដើម*

**វិធានការគ្រប់គ្រង និងកំចាត់**

យើងអាចការពារនិងកំចាត់ជំងឺនេះបានដោយបណ្តុះកូននៅក្នុងកន្ទោងដែលយើងបានសម្លាប់មេរោគនៅក្នុងដីរួច។ ប្រសិនបើ វាធ្វើការបំផ្លាញធ្ងន់ធ្ងរ យើងអាចប្រើថ្នាំមេតាក់សីល (Methaxyl) ឬថ្នាំ ហ្វូសេទីល (Fosetyl-Al) មកបាញ់ការពារនៅលើស្លឹក និង នៅលើដី គឺអាចកាត់បន្ថយជំងឺនេះ ។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម
© CFAP Cambodia 2024

## ៥. ការស្រោចស្រព និងគ្រប់គ្រងទឹក

ត្រូវស្រោចស្រពដំណាំ ឱ្យបានទៀងទាត់ពេលវេលា និងរក្សាសំណើមដីឱ្យស្ថិតនៅក្នុងកម្រិតមួយសមស្របតាមប្រភេទដី។ ចំពោះប្លង់ពិសោធន៍ដែលប្រើកៅស៊ូប្លាស្ទិចគ្របរង យើងអាចស្រោចស្រពតាមវិធីសាស្ត្របង្ហូរទឹកតាមចន្លោះរងនីមួយៗបាន ហើយក្នុងករណីដែលមានភ្លៀងគ្រប់គ្រាន់ ការស្រោចស្រពគឺពុំចាំបាច់ឡើយ ហើយបរិមាណទឹកដែលត្រូវស្រោចគឺពី ៣ - ៥លីត្រ សំរាប់ផ្ទៃដីដាំដុះចំនួន១ម៉ែត្រការេ។

## ៦. ការតាមដានស្រែពិសោធន៍ និងប្រមូលទិន្នន័យ

### ៦.១. ទិន្នន័យរបស់ដំណាំដែលត្រូវប្រមូលរួមមាន

- ឈ្មោះដំណាំ និងប្រភពពូជ
- ផ្ទៃដីដាំដុះសរុប
- ថ្ងៃ.ខែ.ឆ្នាំ បណ្តុះ និងដាំកូនដំណាំ
- ចំនួនគុម្ពដំណាំ ដោយរាប់ក្នុងដំណាក់កាលប្រមូលផលលើកដំបូង
- ថ្ងៃ.ខែ.ឆ្នាំ ដាក់ជីបំប៉ន និងបរិមាណដែលប្រើ
- ទិន្នផល ប្រាក់ចំណូល និងថ្ងៃ.ខែឆ្នាំ ដែលបានប្រមូលផលក្នុងមួយលើកៗ
- វិធីសាស្ត្រស្រោចស្រព
- ប្រភេទសត្វល្អិត និងជំងឺដែលកើតមានច្រើនជាងគេ

### ៦.២. ទិន្នន័យផលិតកម្ម

- កត់ត្រារាល់ការចំណាយ លើសម្ភារផលិតកម្មដោយរាយមុខចំណាយ និង តម្លៃសរុបរបស់សម្ភារនីមួយៗដែលបានទិញសម្រាប់ដំណើរការផលិតកម្ម។
- តម្លៃប្រតិបត្តិនៅលើទីផ្សារ ដូចជាដឹកជញ្ជូន វេចខ្ចប់ ពន្ធលក់ដូរជាដើម។
- តម្លៃពលកម្ម ឧទាហរណ៍ ជួលពលកម្មរៀបចំដី បាញ់ថ្នាំ....។ល។



## ៧. ជំងឺ និង សត្វល្អិត លើសណ្តែក



### ៧.១. ជំងឺរលួយគល់កូនសណ្តែក

គឺជាប្រភេទ ជំងឺផ្សិតម្យ៉ាង ដែលកើតនៅលើសណ្តែក នៅក្នុងដំណាក់កាលដុះលូតលាស់ដំបូង រហូតដល់មុនពេលវាចេញផ្កា ជាពិសេស នៅពេលដែល មានអាកាសធាតុត្រជាក់ និងសំណើមបរិយាកាសខ្ពស់។ យើងអាចធ្វើការការពារជំងឺនេះ ដោយលាយថ្នាំកាប់តាំង ជាមួយគ្រាប់ពូជ មុនពេលយកទៅដាំ ហើយក្នុងករណីយកើតមានឡើងត្រូវបន្ថយការស្រោចស្រព និង បាញ់ថ្នាំព្យាបាល ជំងឺផ្សិតដូចជា ពពួក ម៉ង់ កូហ្សិប ជាដើម ។

### ៧.២. សត្វល្អិតចង្រៃលើសណ្តែកទ្រើង

សត្វល្អិត ដែលបំផ្លាញសណ្តែកទ្រើង ខ្លាំងក្លាជាងគេគឺ ចៃ មមាច រុយដង្កូវស៊ីផ្កា និង ស៊ីផ្លែ ដង្កូវស៊ីរូងកោសិកាស្លឹក។ល។ (សូមមើលឧបសម្ព័ន្ធ២) ដើម្បីការពារ យើងត្រូវប្រើថ្នាំពុលដែលផ្សំពីស្ដៅ (ប្រេងគ្រាប់ស្ដៅ ស្លឹកស្ដៅ សំបកស្ដៅ...) បាញ់ការពារឱ្យបានរៀងរាល់សប្តាហ៍។ ក្នុងករណីយមានការបំផ្លាញធ្ងន់ធ្ងរត្រូវ ប្រើថ្នាំពុលគីមីកសិកម្ម គឺជាជំរើសចុងក្រោយ។ មានថ្នាំពុលមួយចំនួន ដែលមាន ប្រសិទ្ធភាព ដូចជាថ្នាំអាសេហ្វាត acephate ថ្នាំស្ពីណូសាត spinosad ថ្នាំអ៊ីមីដាក្លូព្រីត imidacloprid និងថ្នាំណាល់ naled និង ថ្នាំ Abamectin។ (សូមមើលឧបសម្ព័ន្ធ៤))



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម
© CFAP Cambodia 2024

### ៦.២. ការដាក់ទ្រើងសណ្តែក

ក្រោយពេលជ្រោយដី និងដាក់ជីបំប៉នរួចរាល់ហើយ យើងត្រូវស្រោចទឹកអោយជោគដី (ក្នុងរដូវប្រាំង) មុននឹងរៀបចំទ្រើង។ ទ្រើងសណ្តែក អាចជាមែកឬស្សី ឬ មែកឈើ ដែលមានបណ្តោយប្រវែង២.៥ម៉ែត្រ និងជាមែកឈើទោល ហើយគ្មានបន្លា។ ម្យ៉ាងទៀត យើងអាចយកខ្សែជ័រមួយចំនួនមកធ្វើទ្រើងក៏បាន។

### ៦.៣. ការជួយទប់ស្កាត់សណ្តែកវង្វេងទ្រើង

ពូជសណ្តែកមួយចំនួនអាចបែកមែកយ៉ាងច្រើននៅតាមថ្នាំងផ្នែកខាងក្រោម ហើយមែកទាំងនេះ គឺជាផ្នែកមួយដ៏សំខាន់ សំរាប់កំណត់នូវទិន្នផលរបស់សណ្តែក។ ប្រសិនបើ យើងទុកអោយវាវារចេញឆ្ងាយពីទ្រើង វានឹងធ្វើអោយយើងខាតបង់ទិន្នផលជាមិនខាន ហើយការបែកមែករបស់សណ្តែក គឺមានចំនួនមួយកំណត់ដែរ។ ដូច្នេះ ក្នុងដំណាក់កាលសណ្តែកវារឡើងទ្រើងជាលើកដំបូង យើងត្រូវស្វាហ៍ព្យាយាមបង្វែរមែកសណ្តែកទាំងអស់ ដែលបានបែកចេញមកហើយវារបោះទងនៅលើដី ឬ វារឆ្លង ទៅកាន់ទ្រើងដែលនៅរងផ្សេងមកចង ឬ រុំព័ទ្ធជាមួយទ្រើងរបស់វាវិញ។ ដើម្បីអោយមែកដែលយើងយកមករុំនោះ អាចតោងជាប់ជាមួយទ្រើងបាន យើងត្រូវរុំវាអោយស្របជាមួយនឹងទិសនៃទ្រនិចនាឡិកា។ កិច្ចការទាំងនេះ តម្រូវអោយយើងចំណាយពេលវេលាច្រើន ដែលជាទូទៅអ្នកដាំដុះមិនសូវយកចិត្តទុកដាក់លើសកម្មភាព ដ៏មានសារៈប្រយោជន៍ ទាំងនេះទេ។



# ដំណាំសណ្តែកទ្រើង

សណ្តែកទ្រើង *Vigna unguiculata* ជារុក្ខជាតិវល្លិ ស្ថិតនៅក្នុងគ្រួសារ *Fabaceae* វាមានប្រភពកំណើតមិនច្បាស់លាស់នៅឡើយ អ្នកវិទ្យាសាស្ត្រ ខ្លះបានអះអាងថា វាមានដើមកំណើតនៅប្រទេសឥណ្ឌា ប្រទេសចិន និងប្រទេសអេត្យូពី។ តែថ្មីៗ នេះ គេបានសន្និដ្ឋានថាសណ្តែកទ្រើង មានប្រភពដើមនៅក្នុងប្រទេសអាហ្វ្រិក ហើយបន្ទាប់មកបាន រាលដាលនៅពាសពេញតំបន់ត្រូពិច ។

### ១. លក្ខខណ្ឌនៃការដុះលូតលាស់

សណ្តែកទ្រើងអាចដុះលូតលាស់លើដីច្រើនប្រភេទ និងមានប៉េហាស់ ចាប់ពី 5.5 ដល់7.5។ ប៉ុន្តែប្រភេទដីដែលធ្វើអោយវាដុះលូតលាស់ និង បង្កើនទិន្នផលបានច្រើន គឺជាប្រភេទដីល្បប់ ឬ ដីល្បាយខ្សាច់មានជីជាតិ និង ច្រោះទឹកបានល្អ។ ហើយប៉េហាស់ ដែលល្អបំផុតសំរាប់ សណ្តែកទ្រើង គឺក្នុងចន្លោះពី 5.5 រហូតដល់ 6.5។ ចំពោះសីតុណ្ហភាពវិញ សណ្តែកទ្រើង មានភាពធន់ទ្រាំទៅនឹងកំដៅថ្ងៃហើយនឹងភាពរាំងស្ងួតជាងដំណាំ ដទៃទៀត សីតុណ្ហភាពដី ដែលសមស្របសម្រាប់ដំណុះគ្រាប់គឺចាប់ពី 24-30°C ហើយសីតុណ្ហភាពសមស្របក្នុងតំណាក់កាលលូតលាស់គឺ 25-35°C។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

© CFAP Cambodia 2024

## ២. ការជ្រើសរើសពូជ

ពូជជាកត្តាមួយដ៏សំខាន់ក្នុងចំណោមកត្តាផ្សេងៗទៀត ដែលមានទំនាក់ទំនងជាមួយនឹងកំណើននៃទិន្នផលរបស់សណ្តែក ប៉ុន្តែទីផ្សាក៏ជាកត្តាមួយដ៏សំខាន់ណាស់ដែរ សម្រាប់បង្កើនប្រាក់ចំណូលពីការដាំដុះ។ ដូច្នេះអ្នកដាំដុះ ចាំបាច់ត្រូវតែជ្រើសរើសយកនូវពូជណាដែលមានតម្រូវការនៅលើទីផ្សារ ទើបអាចទទួលបានប្រាក់ចំណូលសមរម្យ ពីការដាំដុះដំណាំនេះ។ ពូជសណ្តែកទ្រើង ដែលគេនិយមដាំ និង អ្នកប្រើប្រាស់ចូលចិត្តទិញ គឺជាប្រភេទសណ្តែក ដែលមានផ្លែពណ៌បៃតង ឬ ពណ៌បៃតងចាស់ ហើយក្លូរវែងៗ។ ចំពោះសណ្តែកទ្រើងដែលមានផ្លែពណ៌ស ឬ បៃតងស្រាល អ្នកប្រើប្រាស់ភាគច្រើន មិននិយមចូលចិត្តទិញយកទៅបរិភោគទេ។ ជាទូទៅ ក្នុងផ្ទៃដី១ហ.ត ត្រូវការបរិមាណពូជសរុបចំនួន ៧ គ.ក្រ ឬ ០.៧ខាំ/១០០ម$^{២}$។







*ពូជក្រុមហ៊ុនអ៊ីស-វ៉េស* *ពូជក្រុមហ៊ុនត្រាំងណុង*



## ៥. បច្ចេកទេសដាំដុះសណ្តែកទ្រើង

ដើម្បីអោយសណ្តែកដុះលូតលាស់ស្មើគ្នាល្អនៅពេលដាំលើកដំបូង យើងត្រូវដាំគ្រាប់មួយចំនួននៅតាមចន្លោះជួរនៃរងនីមួយៗ ដើម្បីទុកសំរាប់គាស់យកទៅដួសនៅតាមរណ្តៅណាដែលមិនដុះ ក្រោយពេលដាំរួចភ្លាមៗ ដើម្បីអោយគ្រាប់សណ្តែកបន្តការបឺតទឹក និងឆាប់ដុះ។

## ៦. ការថែទាំសណ្តែកទ្រើង

### ៦.១. ការស្រោចស្រព

សណ្តែកទ្រើង គឺជាដំណាំដែលមិនសូវត្រូវការទឹកច្រើនប៉ុន្មានទេ ប៉ុន្តែយើងចាំបាច់ត្រូវធ្វើការស្រោចស្រពអោយបានទៀងទាត់។ ក្នុងរដូវវស្សា គេពុំសូវធ្វើការស្រោចស្រពឡើយ ព្រោះមានភ្លៀងធ្លាក់ជាប្រចាំ តែនៅពេលដែលឃើញថា រងសណ្តែកស្ងួតទឹក ហើយស្លឹករបស់វាស្វិតស្រពោនដោយសារកំដៅថ្ងៃខ្លាំង ទើបយើងធ្វើការស្រោចស្រព។ ចំពោះវិធីសាស្ត្រ ស្រោចស្រព គឺធ្វើឡើងតាមរយៈការបង្ហូរទឹកចូលតាមចន្លោះរងនីមួយៗ។ រាល់ការស្រោចស្រពមួយលើកៗ ត្រូវបញ្ចូលទឹកអោយបានកំពស់២/៣ នៃកំពស់រង ហើយរយៈពេលនៃការស្រោចមួយលើកៗ គឺអាស្រ័យទៅតាមប្រភេទដី និង ការប្រែប្រួល នៃអាកាសធាតុ ក្នុងតំបន់ដែលបានដាំដុះ។

សណ្តែកទ្រើង ជាដំណាំដែលអាចស្រូបយកជីអាសូតពីក្នុងបរិយាកាស បានដោយខ្លួនឯង ព្រោះនៅលើឫសរបស់វាមានបាក់តេរីម្យ៉ាង ឈ្មោះថា រីសូប្យូម ដែលជាអ្នកចាប់យកអាសូតមកអោយ ឫសសណ្តែក ដូច្នេះ យើងមិនចាំបាច់ប្រើជីអាសូ៊ត ច្រើនសំរាប់បំប៉នទេ ព្រោះវានាំអោយយើងខាតបង់ថវិកាឥតប្រយោជន៍។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម
© CFAP Cambodia 2024

## ៤. ការប្រើប្រាស់ជី

ការប្រើជីទ្រាប់បាត ប្រើជីធម្មជាតិ ឬ ជីលាមកសត្វក្នុងកម្រិត ៣០ គីឡូក្រាម ក្នុងមួយរងរលាយជាមួយកំបោរកសិកម្មចំនួន ៨ខាំ ក្នុងមួយរង និងជី 15-15-15 ចំនួន ២.៥ ខាំក្នុងមួយរង។ លាយច្របល់ជី និងកំបោរចូលទៅក្នុងដីឱ្យបានស្មើសាច់ល្អ ហើយស្រោចទឹកឱ្យជោគដីល្មម រួចក្រាលកៅស៊ូគ្របលើរង ហើយរក្សាទុករយៈពេលពី ៧-១០ ថ្ងៃមុនពេលដាំ ។

- ប្រើជីប្រភេទ 15-15-15 ក្នុងកម្រិត ១០ក្រាម/គុម្ព ដាក់បង្កប់បាត រណ្ដៅមុនពេលដាំ
- ជីបំប៉នលើកទី១ ដាក់នៅពេលពូនគល់ ឬ ពេលដាក់ទ្រើង ប្រើជី 15-15-15 ក្នុងកម្រិត ១០ក្រាម/គុម្ព ដាក់បង្កប់ក្នុងដីចំនួន២កន្លែង នៅក្បែរគុម្ពចំងាយ ១០សម ពីគល់របស់វា។
- ជីបំប៉នលើកទី២ ដាក់នៅក្រោយពេលប្រមូលផលលើកទី១ ប្រើជីអ៊ុយរ៉េ ក្នុងកម្រិត ១០ក្រាម/គុម្ព ដាក់បង្កប់ក្នុងដីចំនួន២កន្លែង នៅក្បែរគុម្ពចំងាយ ១០ សម ពីគល់របស់វា។
- ជីបំប៉នលើកទី៣ ប្រើជី FDP-IDE ក្នុងកម្រិត១គ្រាប់/គុម្ព ដាក់បង្កប់នៅក្នុងដីក្បែរគុម្ពដំណាំ នៅក្រោយពេលដាក់លើកទី២ បានរយៈពេល ១០-១២ថ្ងៃ ។



© សមាគមសហព័ន្ធកសិករកម្ពុជានៃអ្នកផលិតកសិកម្ម

## ៣. វិធីសាស្ត្ររៀបចំដី និង ដាក់ជីទ្រាប់បាត

សណ្ដែកទ្រើង តម្រូវអោយយើងធ្វើការដាំដុះនៅលើរង ហើយដាំវាជាជួរៗ ដូច្នេះ មុនពេលលើករងយើងត្រូវធ្វើការភ្ជួររាស់ដី អោយបានយ៉ាងតិចចំនួន២ដង ហើយការភ្ជួរដី លើកទី២ គឺក្នុងរយៈពេលយ៉ាងតិច ១សប្ដាហ៍ ក្រោយពេលភ្ជួរ លើកទី១រួច។ លើករង ដែលមានទទឹងប្រវែង ៨០សម និងបណ្ដោយទៅតាមស្ថានភាពដី ចំពោះ ចន្លោះពីរងមួយទៅរងមួយ គឺមានប្រវែង៥០សម ដើម្បីងាយស្រួល រៀបចំទ្រើង និង ប្រមូលផល។ នៅរដូវប្រាំង យើងមិនចាំបាច់លើករងអោយខ្ពស់ពេកទេ កំពស់រងដែលសមស្របសម្រាប់រដូវប្រាំងគឺចាប់ពី ១០-១៥ ស,ម តែនៅរដូវវស្សាវិញ យើងចាំបាច់ត្រូវលើករងឱ្យខ្ពស់ ដើម្បីការពារទឹកលិចរង ក្នុងករណីដែលមានភ្លៀងធ្លាក់ច្រើន និង ធ្វើអោយរងសណ្ដែកឆាប់ស្រក់ទឹកល្អ ដូច្នេះ យើងត្រូវលើករងឱ្យបានកំពស់ ៣០ស.ម ។





© CFAP Cambodia 2024